# 機車法規選擇題

分類編號欄位說明

| 分類編號 | 分類項目內容 |
| --- | --- |
| 11 | 肇事預防、防衛駕駛 |
| 12 | 交通法規 |
| 13 | 急救常識 |
| 14 | 駕駛道德、交通安全常識及行車安全檢查與維護 |
| 15 | 鐵路平交道 |
| 17 | 強制汽車責任保險 |
| 18 | 環保駕駛 |

# 機車法規選擇題

| 題號 | 答案 | 題　　目 | 分類編號 |
|---|---|---|---|
| 001 | 3 | ដើម្បីសំចៃពេលវេលា អ្នកបើកបរអាច ： (1) បើកបរលើសល្បឿនកំណត់ (2) មិនចាំបាច់គោរពកំណត់ចរាចរណ៍ទេ (3) នៅត្រូវតែគោរពកំណត់ចរាចរណ៍ ។ | 11 |
| 002 | 1 | ការបើកបរតាមរបៀបការពារគឺ (1) ការខិតខំចាត់វិធានការសមល្មម ប្រុងប្រយ័ត្នបង្ការកើតឡើងគ្រោះថ្នាក់រថយន្ត (2) មានជំនាញបើកបរល្អប្រសើរ (3) មានទំលាប់រស់នៅល្អប្រសើរ ។ | 11 |
| 003 | 2 | ល្បឿនបើកបរកាន់តែលឿន ចម្ងាយសំរាប់ចាប់ហ្វ្រាំងបញ្ឈប់រថយន្តក៏កាន់តែវែង ប្រសិនបើល្បឿនបង្កើន ១ ដង ចម្ងាយសំរាប់ចាប់ហ្វ្រាំងបញ្ឈប់រថយន្តនឹងបង្កើនប៉ុន្មានដង" (1)២ ដង (2)៤ ដង (3)៨ ដង ។ | 11 |
| 004 | 2 | អ្នកបើកបររថយន្តកាន់តែលឿន ចក្ខុវិស័យរបស់អ្នកបើកបរកាន់តែ ： (1) មិនប្រែប្រួលទេ (2) កាន់តែចង្អៀត (3) កាន់តែធំទូលាយ ។ | 11 |
| 005 | 3 | នៅពេលយប់ អ្នកបើកបររថយន្តត្រូវបើកភ្លើង ប្រសិនបើតំបន់ទីក្រុងមានចង្កៀងភ្លើងបំភ្លឺល្អណាស់ អ្នកបើកបរត្រូវតែ (1) ពាក់វ៉ែនតាមានពណ៌ (2) បើកភ្លើងបំភ្លឺចម្ងាយឆ្ងាយ (3) បើកភ្លើងបំភ្លឺចម្ងាយជិត ។ | 11 |
| 006 | 1 | ក្នុងករណីបើកបររថយន្តឆ្លងកាត់តំបន់ដែលមានទឹកដក់ ： (1) បើកបរដោយល្បឿនទាប (2) បើកបរដោយល្បឿនលឿន (3) ចាប់ហ្វ្រាំងជាញឹកញាយ ។ | 11 |
| 007 | 1 | ក្រោយពេលបង្កគ្រោះថ្នា ក់ ត្រូវតែ (1)ថែរក្សាកន្លែង ប្តឹងប៉ូលីសឱ្យមកដោះស្រាយ (2)គ្មានទំនាក់ទំនងជាមួយខ្ញុំទេ បើកទៅភ្លាម (3)ជជែកតាមមូលហេតុ ដើម្បីកាតព្វកិច្ច។ | 11 |
| 008 | 2 | ក្នុងករណីលោកអ្នកមានយោបល់ខុសគ្នា ចំពោះការវិនិច្ឆ័យភារៈកិច្ចបង្កើតឧប្បត្តិហេតុរថយន្ត ត្រូវតែ" (1) គោរពតាមជាដាច់ខាត (2) ស្នើសុំអង្គការមានសមត្ថកិច្ចធ្វើការវិនិច្ឆ័យសាឡើងវិញ (3) ទៅអង្គការបទបញ្ញត្តិប្តឹងតវ៉ា ។ | 11 |
| 009 | 1 | កាលណាប្តូរខ្សែផ្លូវបើកបរ ដើម្បីចៀសវាងកើតគ្រោះថ្នាក់ដោយសារជ្រោងងាប់របស់ខ្លួន ត្រូវតែ (1 )បើកភ្លើងបង្ហាញទិសដៅទុកជាមុន មើលកញ្ចក់បញ្ចាំងខាងក្រោយ ហើយងាកក្បាលមើល (2)សំឡឹងមើលខាងមុខ ប្រុងប្រយ័ត្នស្ថានភាពផ្លូវ (3)រក្សាចម្ងាយសុវត្ថិភាពពីយានយន្តខាងមុខ។ | 11 |
| 010 | 1 | នៅខាងក្រោមនេះ តើប្រការណាសមស្របនឹងគំនិតបើកបរតាមវិធីការពារ? (1 )ទោះជាខ្លួនឯងគោរពតាមក្បួនខ្នាតចរាចរណ៍ក៏ដោយ នៅត្រូវតែប្រុងប្រយ័ត្នគេល្មើសច្បាប់ធ្វើខូចខាតដល់ខ្លួនឯ (2)ជ្រើសរើសយានយន្តដែល (3) | 11 |

# 機車法規選擇題

| 題號 | 答案 | 題　　目 | 分類編號 |
|---|---|---|---|
| 011 | 1 | អំពីការរៀបរាប់ចម្ងាយសុវត្ថិភាពសំរាប់បើកបរយានយន្ត នៅខាងក្រោមនេះ ប្រការណាខុសហើយ?（1）ដោយសារដងខ្លួនម៉ូតូមានទំហំតិចតួច ដូច្នេះ បើសិនបើកនៅខាងក្រោយម៉ូតូ ចម្ងាយសុវត្ថិភាពប្រៀបធៀបនឹងរថយន្តដែលមានល្បឿនដូចគ្នា អាចបន្ថយបន្តិចបាន（2）ទោះបីនៅពេលបញ្ឈប់យានយន្ត ក៏ត្រូវតែរក្សាចម្ងាយសុវត្ថិភាពដែរ（3）ក្រោយពីត្រូវយានយន្តវ៉ាឡាន ត្រូវតែបន្ថយល្បឿនបន្តិច ដើម្បីរក្សាចម្ងាយសុវត្ថិភាពថ្មីទៀត។ | 11 |
| 012 | 2 | អំពី「សេចក្តីណែនាំស្តីពីការទិញមួកសុវត្ថិភាព」 នៅខាងក្រោមនេះ ប្រការណាខុសហើយ?（1）ត្រូវបិទស្លាកពេញលក្ខណៈការត្រួតពិនិត្យដែលទទួលស្គាល់ដោយមន្ទីរត្រួតពិនិត្យស្តង់ដារ（2）ក្រោយពីមួកសុវត្ថិភាពត្រូវប៉ះទង្គិចដោយកម្លាំងខ្លាំង បើសិនខាងក្រៅមិនទាន់ខូចខាត ក៏មិនបាច់ផ្លាស់ប្តូរទេ（3）ត្រូវជ្រើសរើសមួកសុវត្ថិភាពមានពណ៌ស្រស់ ឬមានសម្ភារៈចាំងពន្លឺ។ | 11 |
| 013 | 2 | សូមសួរថា តើជ្រើសរើសមួកសុវត្ថិភាពតាមបែបណាល្អជាង?（1）ប្រើមួកសុវត្ថិភាពសំរាប់វិស្វកម្ម ស្រាលផង ងាយខ្យល់បក់ចូលផង（2）ជ្រើសរើសមួកដែលបិទស្លាកពេញលក្ខណៈការត្រួតពិនិត្យដែលទទួលស្គាល់ដោយមន្ទីរត្រួតពិនិត្យស្តង់ដារ អាចធានាសុវត្ថិភាព（3）ជ្រើសរើសមួកមានពណ៌ជ្រៅ អាចធន់ភាពកខ្វក់បាន។ | 11 |
| 014 | 3 | អំពីការណែនាំស្តីពីចម្ងាយខុសគ្នានៃកង់ខាងក្នុង ប្រការណាខុសហើយ?（1）កាលណាយានយន្តបត់របត់ កង់ខាងក្រោយនឹងឆៀងទៅខាងក្នុង（2）គម្លាតភ្លៅនៃរថយន្តកាន់តែវែង ចម្ងាយខុសគ្នានៃកង់ខាងក្នុងនឹងកាន់តែច្រើន（3）រថយន្តដឹកអ្នកដំណើរធុនតូចគ្មានចម្ងាយខុសគ្នានៃកង់ខាងក្នុងទេ។ | 11 |
| 015 | 1 | កាលណាអ្នកជិះម៉ូតូបើកឆ្លងកាត់ផ្លូវមានទឹក ត្រូវតែបើកបរតាមរបៀបណាល្អជាង?（1）បើកបរដោយល្បឿនយឺត（2）ចាប់ហ្វ្រាំងច្រើនដង（3）ឆ្លងកាត់ឆាប់រហ័ស។ | 11 |
| 016 | 2 | មុនពេលបត់របត់នៅមាត់ផ្លូវខ្វែង អ្នកជិះម៉ូតូមិនត្រូវធ្វើអំពើអ្វី?（1）បន្ថយល្បឿន ឱ្យគេបើមុន（2）បើកភ្លើងក្បាលម៉ូតូ（3）បើកភ្លើងបង្ហាញទិសដៅ។ | 11 |
| 017 | 2 | កាលណាជិះម៉ូតូ បើសិនរកឃើញប្រព័ន្ធហ្វ្រាំងខុសហើយ ពេលដំបូង ត្រូវធ្វើយ៉ាងដូចម្តេចល្អជាង?（1）បើកភ្លើងក្បាលម៉ូតូ（2）លែងឈ្នាន់ល្បឿន（3）ចុចស៊ីផ្លេ។ | 11 |
| 018 | 1 | កាលណាជិះម៉ូតូ បើសិនមើលឃើញមានបាល់រត់ដល់ផ្លូវពីក្បែរផ្លូវ ត្រូវតែ（1）បន្ថយល្បឿនបើកយឺត កាន់ដងដៃខ្ជាប់（2）ចៀសផុតពីបាល់ ឆ្លងកាត់ឆាប់រហ័ស（3）ចុចស៊ីផ្លេ ជិះដល់ផ្លូវផ្ទុយទិសដៅ។ | 11 |

| | | | |
|---|---|---|---|
| 019 | 2 | កាលណាជិះម៉ូតូឆ្លងកាត់កំណាត់ផ្លូវមានផ្សែងធូលី ត្រូវតែបើកបរយ៉ាងដូចម្តេច? (1<br>)បើកនៅក្បែរយានយន្តធុនធំ អាចមើលច្បាស់នូវស្ថានភាពផ្លូវ (2) បន្ថយល្បឿនបើកយឺតៗ<br>(3) ឆ្លងកាត់ឆាប់រហ័ស ។ | 11 |
| 020 | 2 | កាលណាជិះម៉ូតូនៅពេលយប់ អ្នកបើកបរមិនងាយមើលឃើញវត្ថុបែបណា (1) អ្នកដំណើរកំពុងដើរ<br>(2) មនុស្សឈរឡើង (3) យានយន្តកំពុងបើកបរ ។ | 11 |

| 題號 | 答案 | 題　　目 | 分類編號 |
|---|---|---|---|
| 021 | 2 | ហេតុអ្វីបានជា អ្នកជិះម៉ូតូគោរពច្បាប់ គឺ ៖ (1) ពីព្រោះគេភិតភ័យត្រូវដកហូតប័ណ្ណ ផ្តន្ទាទោស<br>ទើបគោរពតាមច្បាប់ (2) គោរពច្បាប់ដើម្បីភារះកិច្ច កិត្តិយសនិងសន្តិសុខ (3) ពីព្រោះមានប៉ូលិសត្រួតពិនិត្យ<br>ហេតុនេះគោរពតាមច្បាប់ | 11 |
| 022 | 2 | អ្នកបើកបរត្រូវតែ (1) យកចិត្តទុកដាក់ចំពោះបច្ចេកទេសបើកម៉ូតូ (2) ធានាសុវត្ថិភាព<br>(3) ដើម្បីទៅដល់ទីគោលដៅ បើកត្រង់តែម្តង ។ | 11 |
| 023 | 1 | នៅខាងក្រោមនេះ តើប្រការណា 「 មិនមែន 」 អំពើគ្រោះថ្នាក់នៅពេលជិះម៉ូតូទេ? (1<br>)ជិះម៉ូតូដឹកមនុស្សនៅកៅអីខាងក្រោយ (2) ចូលរួមក្រុមម៉ូតូ បើកដោយល្បឿនលឿននៅពេលយប់<br>(3) ប្រជុំគ្នាជប់លៀង ជិះដើរលេងក្រោយពេលផឹកស្រា ។ | 11 |
| 024 | 3 | ទតង ដល ជ មត រងកយ ផ<br>កខងលលខនរបស" អកតត5វ" (1) លៃ9 លុម8ខ (2)<br>លលអង ថយលតកយ (3) ល ្ផត សត ្ក។ | 11 |
| 025 | 1 | នៅពេលរថយន្តបើកបរនៅលើផ្លូវរបត់ ល្បឿនកាន់តែលឿន<br>កម្លាំងឃ្លាតចាកមជ្ឈមណ្ឌលដែលបានបង្កើតឡើងនឹង (1) កាន់តែច្រើនជាង (2) កាន់តែតូចជាង<br>(3) មិនប្រែប្រួលទេ | 11 |
| 026 | 2 | ល ្ល១លមត ្នករថប" ហ៤៥ងបន៧ន" មនអថ<br>ថបន ក ្ង លតថនល១ក ខណ្ល១លផដល<br>តត5វបនថក" ល ្ល ្យយក សបកកង" (1) នង<br>ករល? ផលង បទលបក ផដលជ ករតតត១នត ្<br>ហ៤៥ង កង" ខងលតកយ បន៧ប" ១ (2) ល? ផលង<br>បទលបក ល?យលតប ផ កខងម8ខនង | 11 |

| | | | |
|---|---|---|---|
| | | ខងលតកយ ហ៤៥ង（3）ផលង បទលបក្ស<br>ករតតត១នត្យនន ហ៤៥ង កង" ម៨ខ។ | |
| 027 | 2 | កាលណាជិះម៉ូតូ កាយវិការកែងដៃត្រឹមត្រូវជាបែបណា?（1）លាតត្រង់ទៅមុខ（2）អែបទៅដងខ្លួន<br>（3）លាតត្រដាងទៅក្រៅ។ | 11 |
| 028 | 3 | ចំពោះអ្នកបាក់ឆ្អឹង ភាន់ភាំងក្នុងគ្រោះចរាចរណ៍ ត្រូវតែ（1）កុំផ្លាស់ទៅកន្លែងផ្សេងទៀត លើកលែងតែស្ថានភាពជាបន្ទាន់（2）មុនពេលរើសអ្នករបួស ត្រូវតែដោះស្រាយស្ថានភាពដូចជា ពិបាកដកដង្ហើម ហូរឈាម បាក់ឆ្អឹងជាដើម（3）រួមប្រការខាងលើទាំងអស់។ | 11 |
| 029 | 1 | កាលណាជួបគ្រោះថ្នាក់ចរាចរណ៍ អ្នករបួសសន្លប់ហើយ ទឹកមុខនឹងមានពណ៌（1）ស្លេកស្លាំង<br>（2）ពណ៌ប្រផេះដូចជាសំណ（3）រោគសញ្ញាឡើងក្រហម។ | 11 |
| 030 | 2 | បើសិនផ្លូវខាងមុខកើតឧប្បត្តិហេតុ ប៉ូលីសបានដល់ទីកន្លែងដោះស្រាយ យើងត្រូវធ្វើយ៉ាងដូចម្តេចល្អជាង?（1）បណ្ឈប់ក្បែរផ្លូវមើលឃើញ（2）ចេញពីផ្លូវនេះ កុំឈប់នៅនឹងកន្លែងមើល（3）ឈប់នៅកន្លែងដដែល ជួយប៉ូលីស ហើយថែករំលែករូបថត។ | 11 |

| 題號 | 答案 | 題　　目 | 分類編號 |
|---|---|---|---|
| 031 | 2 | ក្រោយពីផឹកស្រា អាចជិះម៉ូតូបានឬទេ?（1）បាន（2）ទេ（3）អាចជិះយឺត។។ | 11 |
| 032 | 1 | កាលណាអ្នកជិះម៉ូតូមើលឃើញយានយន្តផ្សេងទៀតឬអ្នកដំណើរមានអំពើមិនល្អ ក៏ចេះតែបង្ហាញអានុភាព ងាយរជើបរំជួល ត្រូវតែធ្វើយ៉ាងដូចម្តេចដើម្បីអត់ធន់ចិត្តខ្លួន?（1）អត់ធន់ ឱ្យគេដើរមុន<br>（2）ជជែកតាមមូលហេតុ（3）សងសឹក។ | 11 |
| 033 | 2 | កាលណាជិះម៉ូតូ ត្រូវប្រុងប្រយ័ត្នចំពោះ（1）ហាងលក់ទំនិញនៅក្បែរផ្លូវ（2）សញ្ញាភ្លើង បទបញ្ជានៃសញ្ញានិងសភាពបើកបរនៃយានយន្តខាងមុខ（3）រួមប្រការខាងលើទាំងអស់។ | 11 |
| 034 | 1 | កាលណាជិះម៉ូតូ ត្រូវតែ（1）សម្លឹងចំពោះខាងមុខ ហើយយកចិត្តទុកដាក់ចំពោះយានយន្តនៅក្បែរឆ្វេងនិងស្តាំ<br>（2）មើលឆ្វេងម្តង មើលស្តាំម្តង ហើយអាចស៊ីផឹកម្ហូបអាហារបាន<br>（3）លេងជាមួយអ្នកដំណើរអង្គុយនៅកៅអីខាងក្រោយ។ | 11 |

| | | | |
|---|---|---|---|
| 035 | 1 | កាលណាយានយន្តធុនធំឆ្លងកាត់ ដូចជាបំពង់ស្រូបខ្យល់ អាចបង្កើតកម្លាំងស្រូបខ្លាំង ដូច្នេះ កាលណាបើកនៅក្បែរយានយន្តធុនធំឬជួបយានយន្តធុនធំ ត្រូវតែ (1)កាន់ដងដៃឱ្យខ្ជាប់ (2)បន្ទូរដងខ្លួន (3)អត់បញ្ហា មិនបាច់ប្រុងប្រយ័ត្ន។ | 11 |
| 036 | 2 | កាលណារថយន្តបត់របត់ គម្លាតភ្លៅនៃរថយន្តកាន់តែវែង ចម្ងាយខុសគ្នានៃកង់ខាងក្នុងនឹងកាន់តែច្រើន មានន័យថា ត្រូវការទទឹងផ្លូវក៏ (1)កាន់តែតិច (2)កាន់តែច្រើន (3)មិនប្រែប្រួលទេ។ | 11 |
| 037 | 2 | កាលណាជិះម៉ូតូឆ្លងកាត់ផ្លូវមានទឹក ត្រូវតែប្រុងប្រយ័ត្នជាពិសេស (1)សាកល្បងបើកភ្លើង (2)សាកល្បងចាប់ហ្វ្រាំង (3)សាកល្បងបង្វិលឈ្នាន់ល្បឿនបន្ថែមប្រេងសាំង។ | 11 |
| 038 | 3 | កាលណាបត់របត់ កើតឡើងគ្រោះថ្នាក់ចរាចរណ៍ មូលហេតុគឺ ដោយសារ អ្នកជិះម៉ូតូ (1)ធ្វេសប្រហែសតែមុមងាប់នៃចក្ខុវិស័យ (2)ធ្វេសប្រហែសតែចម្ងាយខុសគ្នានៃកង់ខាងក្នុង (3)រួមប្រការខាងលើទាំងអស់។ | 11 |
| 039 | 2 | កាលណាពិនិត្យហ្វ្រាំងនៃម៉ូតូ ចាប់ដងទាញហ្វ្រាំង ត្រូវតែរក្សាទុកចម្លោះប៉ុន្មាន? (1)មិនត្រូវទុកមានចម្លោះទេ (2)ត្រូវទុកចម្លោះ១ដល់២សង្ទីម៉ែត្រ (3)ត្រូវទុកចម្លោះលើសពី៣ដល់៤សង្ទីម៉ែត្រ។ | 11 |
| 040 | 2 | តើចំណែកណាក្នុងដងខ្លួនមនុស្សត្រូវប៉ះទង្គិច នឹងងាយបណ្តាលការស្លាប់ឬសំណល់រោគជាងគេ? (1)អវយវះ (2)ក្បាល (3)ខ្នង។ | 11 |
| 041 | 3 | នៅពេលជួបប្រទះក្បួនរថយន្តប៉ូលិស : (1) អនុញ្ញាតបើកបរចូលក្នុងក្បួនរថយន្ត (2) បើកឱ្យលឿន (3) មិនអនុញ្ញាតបើកបរចូលក្នុងក្បួនរថយន្តទេ ។ | 11 |
| 042 | 1 | ចំពោះអ្នកជិះម៉ូតូ រឿងសំខាន់ជាងគេគឺ (1)ត្រូវមានគំនិតសិលធម៌អំពីការយកចិត្តទុកដាក់សន្តិសុខចរាចរណ៍សាធារណៈ (2)អាចបើកបររថយន្តឱ្យលឿនដើម្បីសំចៃពេលវេលា (3)យកចិត្តទុកដាក់ចំពោះទិដ្ឋភាពតាមផ្លូវ។ | 11 |

| 題號 | 答案 | 題　　目 | 分類編號 |
|---|---|---|---|
| 043 | 3 | ប្រសិនបើមានកំអែលប្រេងនៅលើផ្លូវ បណ្តាលឱ្យលោកអ្នកជិះម៉ូតូរំអិលដួល លោកអ្នកត្រូវតែ (1)យល់ឃើញថាខ្លួនឯងមានអកុសល ដើរចាកចេញពីនេះ (2)មិនចាំបាច់ទៅនាយកដ្ឋានប៉ូលិសជិតជាងដើម្បីប្តឹប៉ូលិស (3)យកមែកឈើឬសញ្ញាទៀតដាក់នៅសងខាង ដើម្បីដាស់តឿនរថយន្តបើកបរទៅវិញទៅមកឱ្យប្រុងប្រយ័ត្ន ។ | 11 |
| 044 | 3 | កាលណាបើកបរយានយន្តនៅជាយក្រុង ឃើញហ្វូងក្ងានឆ្លងកាត់ផ្លូវ ត្រូវតែ (1)ចុចស៊ីផ្លេសំឡេងធំជំរុញហ្វូងក្ងានឆ្លងកាត់ឆាប់រហ័ស (2)បង្កើនល្បឿន ឆ្លងកាត់ហ្វូងក្ងាន (3)បន្ថយល្បឿនបើកយឺតៗ ចាំហ្វូងក្ងានឆ្លងកាត់រួច ទើបបើកទៅខាងមុខ។ | 11 |

| | | | |
|---|---|---|---|
| 045 | 1 | នៅពេលសញ្ញាគ្រប់គ្រងរថយន្តបានបង្ហាញភ្លើងក្រហម ៖ （1） ហាមឃាត់មិនឱ្យឆ្លងកាត់ （2） រថយន្តដែលបែរស្តាំអាចបើកទៅទៀត （3） ប្រសិនបើស្ថានភាពចរាចរណ៍អនុញ្ញាត រថយន្តអាចបែរឆ្វេងបាន ។ | 11 |
| 046 | 1 | ប្រសិនបើអ្នកជិះម៉ូតូចង់ថែរក្សាសណ្តាប់ធ្នាប់ល្អ ជំរុញសន្តិសុខសង្គមនិងសុភមង្គលគ្រួសារនៅវិស័យចរាចរណ៍លោកអ្នកត្រូវតែមាន ៖ （1）សិលធម៌បើកបរនិងគំនិតគោរពច្បាប់ （2）មានបច្ចេកទេសបើកបរល្អប្រសើរ（3）មិនហូបបារី ហើយមិនផឹកស្រាទេ ។ | 11 |
| 047 | 1 | ក្នុងករណីអ្នកបើកបររថយន្តបានបុកអ្នកដំណើរ ដោយមិនប្រុងប្រយ័ត្ន ត្រូវតែ ៖ （1）មានស្មារតីទទួលខុសត្រូវដ៏ខ្ពង់ខ្ពស់ ខំប្រេងប្រែងជួយសង្គ្រោះ （2）បង្កើនល្បឿនបើករថយន្តរត់គេច（3）លួងលោមអ្នករងរបួសដើម្បីដោះស្រាយរឿង ។ | 11 |
| 048 | 1 | នៅពេលអ្នកជិះម៉ូតូបើកបរនៅលើផ្លូវ សភាពការណ៍ផ្លូវនិងចរាចរណ៍បានប្រែប្រួលហើយ ចំពោះការប្រែប្រួល អ្នកជិះម៉ូតូត្រូវតែចាត់វិធានការ ៖ （1） បន្ថយល្បឿនបើកបរដោយមិនច្រឡោតនិងគ្មានតក់ស្លុត （2） បង្កើនល្បឿនឆ្លងកាត់（3） ខំប្រេងប្រែងមិនបើកបរនៅលើផ្លូវថ្មល់ទាំងនេះ ។ | 11 |
| 049 | 2 | ការថែរក្សាការពារសណ្តាប់ធ្នាប់ចរាចរណ៍ ធានាសន្តិសុខនៃការបើកបររថយន្ត តើនរណាត្រូវធ្វើជាតួយ៉ាង នៅពេលដំបូង ៖ （1） អង្គការគ្រប់គ្រងចរាចរណ៍（2） អ្នកបើកបរ （3） អ្នកដំណើរ ។ | 11 |
| 050 | 3 | ក្នុងករណីដែលអ្នកជិះម៉ូតូជួបប្រទះរឿងមិនសប្បាយចិត្ត តាមធម្មតា គេមានគុណវិបត្តិធំសម្បើមគឺ ៖ （1） អត់មានសិលធម៌មនុស្សជាតិ （2） អត់មានចិត្តករុណា （3） មានកំហឹងយ៉ាងខ្លាំង ។ | 11 |
| 051 | 1 | កត្តាសំខាន់សំរាប់អ្នកជិះម៉ូតូធ្វើការដោះស្រាយរឿងស្មុគស្មាញនិងគ្រោះថ្នាក់ គឺ ៖ （1） ដោះស្រាយដោយគ្មានតក់ស្លុត ហើយធានាសន្តិសុខ （2） ប្រថុយទៅដោះស្រាយរឿង （3） មានមោកភាពដោះស្រាយតាមធម្មតា ។ | 11 |
| 052 | 1 | សត្រូវធំសម្បើមរបស់អ្នកជិះម៉ូតូ គឺ ៖ （1） ធ្វេសប្រហែស （2） ឧបសគ្គនៅលើផ្លូវ （3） បសុសត្វនៅលើផ្លូវ ។ | 11 |

| 題號 | 答案 | 題　　目 | 分類編號 |
|---|---|---|---|
| 053 | 3 | ចំពោះសំលៀកបំពាក់និងទឹកមុខរបស់អ្នកជិះម៉ូតូ ៖ （1）គ្មានកំរិតទេ （2）អាចពាក់ស្បែកជើងផ្ទាត់（3）ត្រូវស្អាតបាត ។ | 11 |

| | | | |
|---|---|---|---|
| 054 | 1 | នៅពេលជិះម៉ូតូទៅហាងលក់ទំនិញទិញទំនិញ អ្នកជិះម៉ូតូត្រូវតែ ： (1) ចតម៉ូតូនៅកន្លែងកំណត់ឱ្យបានល្អមសិន សឹមចូលក្នុងហាងលក់ទំនិញ (2)<br>ចតម៉ូតូនៅផ្លូវហៅស្រែកអ្នកលក់ទំនិញជូនទំនិញចេញពីហាងលក់ ទំនិញ<br>(3)ចតម៉ូតូនៅខាងមុខកុងទ័រនៃទ្វារហាងលក់ទំនិញឬផ្លូវសំរាប់អ្នកដំណើរដើរតាមទំនើងចិត្ត ។ | 11 |
| 055 | 2 | ក្នុងករណីរថយន្តទាំងពីរជួបប្រទះនៅផ្លូវចង្អៀត អ្នកបើកបរត្រូវតែ ： (1) បើករថយន្តទៅមុខមុនគេដើម្បីបង្ខំគេជៀសផ្លូវ (2) ៉ាន់ស្មានកន្លែងធំទូលាយសំរាប់បញ្ឈប់រថយន្ត ទុកជាមុន<br>បញ្ឈប់រថយន្តនៅក្បែរផ្លូវដោយអាចធ្វើបាន ឱ្យរថយន្ត គេបើកបរសិន (3) ចុចស៊ីផ្លេឱ្យស្រែកយ៉ាងខ្លាំងដើម្បីព្រមានគេជៀសផ្លូវឱ្យខ្លួនឯង ។ | 11 |
| 056 | 3 | ពីព្រោះម៉ូតូមានល្បឿនយឺត ប្រសិនបើបានស្ដាប់រថយន្តខាងក្រោយបានចុចស៊ីផ្លេសុំជៀសផ្លូវ<br>អ្នកជិះម៉ូតូត្រូវតែធ្វើ យ៉ាងដូចម្ដេច" (1) បញ្ឈប់ម៉ូតូភ្លាម ឱ្យគេបើកផុតទៅ (2) បើកបរតាមខ្សែផ្លូវដើមមិនអើពើគេទេ (3) បើកបរតាមខ្សែផ្លូវខាងស្ដាំ ហើយបើកភ្លើងបង្ហាញទិសដៅ<br>ឬវាយកាយវិកាដៃបញ្ហាញថាអាចជៀសផ្លូវបាន។ | 11 |
| 057 | 3 | ការបើកបរយានយន្តនៅពេលយប់ ឃើញនៅកន្លែងឆ្ងាយ យានយន្តបើកមកពីទិសដៅផ្ទុយស្នើសុំឱ្យគេបើកមុន ត្រូវតែ : (1)បើកភ្លើងបញ្ចាំងទៅឆ្ងាយ និងចុចស៊ីផ្លេសំឡេងធំៗ ព្រមានយានយន្តបើកមក<br>ហើយបង្កើនល្បឿនបើកទៅខាងមុខ (2)បញ្ឈប់យានយន្តនៅនឹងកន្លែងភ្លាម ហើយបិទភ្លើងទាំងអស់<br>ចាំយានយន្តបើកមកឆ្លងកាត់ (3)បើកភ្លើងបញ្ចាំងទៅជិត ហើយបន្ថយល្បឿនដើម្បីជួបយានយន្តបើកមក។ | 11 |
| 058 | 1 | នៅក្នុងសង្គមឧស្សាហកម្ម ពេលវេលាគឺជាមាសជាប្រាក់ តែចំពោះអ្នកជិះម៉ូតូម្នាក់ ត្រូវយកចិត្តទុកដាក់ចំពោះ"<br>(1) សន្តិសុខសំខាន់ជាងពេលវេលា (2) គ្រឿងបរិក្ខារចរាចរណ៍ (3) មុខសណ្ឋានម៉ូតូ ។ | 11 |
| 059 | 3 | នៅដំណើរផ្លូវ ប្រសិនបើលោកអ្នកចាប់អារម្មណ៍ថា ស្មា រតី នឿយហត់ ហើយងងុយដេក<br>លោកអ្នកត្រូវធ្វើយ៉ាងដូចម្ដេច" (1) បន្តបើកបររថយន្ត (2) លុបថ្នាំ មួយចំនួន ដាស់ស្មារតី<br>បើករថយន្តតាមធម្មតា (3) បញ្ឈប់រថយន្តនៅក្បែរផ្លូវជិតជាងគេ ចុះរថយន្ត ហើយសំរាកមួយភ្លែត<br>ក្រោយពេលស្មារតីល្អប្រសើរឡើង ទើបបើករថយន្តទៅ ។ | 11 |
| 060 | 1 | នៅពេលភ្លៀង ចាប់ហ្វ្រាំងជាបន្ទាន់ រថយន្តនឹង" (1) រំអិលដួល (2) ងាយបញ្ឈប់រថយន្តដោយនឹងន (3)<br>ដូចពេលធម្មតា ។ | 11 |
| 061 | 2 | ពេលយប់ជ្រៅ នៅផ្លូវជាយក្រុង ក្នុងករណីដែលនៅលើផ្លូវធំ លូលាយ ហើយគ្មានរថយន្តឯទៀតផងគ្មាន<br>អ្នកដំណើរផង" (1) អាចហាត់បើកបររថយន្តឱ្យលឿនដោយល្បឿនលឿន<br>(2) ត្រូវបើកបររថយន្តតាមល្បឿនកំណត់ (3) អាចលើសល្បឿនកំណត់បន្តិច | 11 |

| 題號 | 答案 | 題　　目 | 分類編號 |
|---|---|---|---|

| | | | |
|---|---|---|---|
| 062 | 2 | នៅពេលយាមល្បាតតាមផ្លូវ ប៉ូលិសចរាចរណ៍(ផ្លូវថ្នល់)នឹងត្រួតពិនិត្យអំពើបំពានច្បាប់ចរាចរណ៍ ការងារនេះនឹង ៖ （1）នឹងខូចប្រយោជន៏របស់អ្នកបើកបរ ។（2）មានប្រយោជន៏ដល់អ្នកបើកបរ ។（3）គ្មានទំនាក់ទំនងជាមួយនឹងអ្នកបើកបរទេ ។ | 11 |
| 063 | 3 | មុនពេលនឹងបើករថយន្ត អ្នកបើកបររកឃើញហ្វ្រាំងរថយន្តឬចង្កូតបានខុសហើយ ត្រូវតែ ៖ （1）បើកបរតាមធម្មតា ។（2）បើកឱ្យយឺតក៏បាន។（3）បញ្ឈប់បើកបររថយន្ត ។ | 11 |
| 064 | 2 | ប្រសិនបើ រថយន្តបើកលឿនតាមដែនរថយន្តរំលត់អគ្គិភ័យ ទង្វើនេះ ៖ （1）អាចធ្វើដូចយ៉ាងនេះ（2）ហាមប្រាមមិនឱ្យធ្វើដូចយ៉ាងនេះទេ（3）គ្មានកំណត់ទេ ។ | 11 |
| 065 | 3 | ល្បឿននៃរថយន្តកាន់តែលឿន ចម្ងាយសំរាប់បញ្ឈប់រថយន្តនឹង ៖ （1）មិនប្រែប្រួល（2）កាន់តែខ្លី（3）កាន់តែវែង ។ | 11 |
| 066 | 2 | ល្បឿននៃរថយន្តកាន់តែលឿន បានបង្កើនកម្លាំងសន្ទុះ（1）កាន់តែតូច（2）កាន់តែធំឡើង（3）មិនប្រែប្រួលទេ ។ | 11 |
| 067 | 1 | នៅពេលយប់ រថយន្តដែលបើកបរនៅខាងក្រោយពីរថយន្តឯទៀត អ្នកបើកបរត្រូវតែ ៖ （1）បើកភ្លើងបំភ្លឺចម្ងាយជិត（2）បើកភ្លើងបំភ្លឺចម្ងាយឆ្ងាយ（3）មិនចាំបាច់បើកភ្លើងទេ ។ | 11 |
| 068 | 3 | នៅពេលជិះម៉ូតូនៅក្នុងផ្លូវរូង ៖ （1）មិនអនុញ្ញាតបើកភ្លើងទេ（2）អាចបើកភ្លើង ហើយបង្កើនល្បឿនបើកឱ្យលឿន（3）ត្រូវតែបើកភ្លើង ហើយបន្ថយល្បឿនបើកឱ្យយឺត ។ | 11 |
| 069 | 3 | នៅពេលភ្លើងក្រហមបានបំភ្លឺ ផ្លូវសំរាប់អ្នកដំណើរឆ្លងកាត់គ្មានមនុស្សដើរកាត់ ហើយគ្មានរថយន្តច្រើននៅលើផ្លូវចំហអ្នកបើកបរអាច ៖ （1）បើកបរទៅខាងមុខ（2）បើកបរបែរស្តាំ（3）ហាមឃាត់មិនឱ្យបើកបរ ។ | 11 |
| 070 | 1 | ខ្ញុំជាអ្នកបើកបរល្អប្រសើរ មួយរូប ហើយគោរពតាមបទបញ្ញត្តិចរាចរណ៍នៅគ្រប់ពេលគ្រប់កន្លែង ខ្ញុំសង្ឃឹមថា ដើម្បីធានាសន្តិសុខចរាចរណ៍ ប៉ូលិសចរាចរណ៍(ផ្លូវថ្នល់)ត្រូវតែ ៖ （1）បង្កើនការត្រួតពិនិត្យ ហើយហាមប្រាមអំពើល្មើសបទបញ្ញត្តិចរាចរណ៍ដោយម៉ឺងម៉ាត់（2）មិនចាំបាច់ត្រួតពិនិត្យនិងហាមប្រាមអំពើល្មើសបទបញ្ញត្តិចរាចរណ៍ទេ（3）ត្រូវតែត្រួតពិនិត្យ មិនចាំបាច់ហាមប្រាមអំពើល្មើសបទបញ្ញត្តិចរាចរណ | 11 |

| | | | |
|---|---|---|---|
| 071 | 1 | យើងទាំងអស់គ្នាសុទ្ធតែទទួលខុសត្រូវចំពោះសន្តិសុខចរាចរណ៍ ក្រោយពីយើង<br>ខ្ញុំត្រូវតែគោរពបទបញ្ញត្តិចរាចរណ៍ ប្រសិនបើយើងមើលឃើញអ្នកណា<br>រថយន្តណាបានល្មើសបទបញ្ញត្តិចរាចរណ៍ និងមានឧប្បត្តិហេតុចរាចរណ៍ ត្រូវតែ ： （1）<br>ជំរាបការពិតឱ្យអង្គការប៉ូលិសឱ្យដឹងឧប្បត្តិហេតុចរាចរណ៍ គ្រប់នៅពេលវេលានិងគ្រប់ទីកន្លែង<br>ហើយជួយធ្វើការ ដោះស្រាយឧប្បត្តិហេតុនោះ （2） មិនអើពើឧប្បត្តិហេតុនោះ （3）<br>មិនរាយការឧប្បត្តិហេតុនោះ ។ | 11 |

| 題號 | 答案 | 題　　目 | 分類編號 |
|---|---|---|---|
| 072 | 3 | នៅពេលអ្នកបើកបរល្អប្រសើរបើកបររថយន្ត គេត្រូវតែ ： （1） បើកបររថយន្តឱ្យលឿន （2）<br>បើកបររថយន្តឱ្យយឺត （3） បើកបររថយន្តដោយល្បឿនសមល្មម ។ | 11 |
| 073 | 2 | ប្រសិនបើជួបប្រទះប្រេងសាំងបានឆេះហើយ ត្រូវតែធ្វើយ៉ាងដូចម្តេច ： （1）រំលត់ភ្លើងនឹងទឹក<br>（2）រំលត់ភ្លើងនឹងប្រដាប់ពន្លត់អគ្គិភ័យនិងខ្សាច់ ឬភួយ ខោអាវដែលបានជ្រលក់ទឹក<br>（3）រំលត់ភ្លើងនឹងមែកឈើនៅជិតខាង ។ | 11 |
| 074 | 2 | នៅលើម៉ូតូ ： （1）អាចពាក់រថយន្តនៅសងខាង （2） មិនអនុញ្ញាតពាក់រថយន្តនៅសងខាង<br>（3）គ្មានកំណត់ទេ | 11 |
| 075 | 3 | នៅពេលជិះម៉ូតូជិតដលផ្លូវរថភ្លើងកាត់គ្នា ក៏ឃើញរបងដាក់ចុះជាសន្សឹម។ នៅខាងមុខមានម៉ូតូជាច្រើន សុទ្ធតែ<br>បង្កើនល្បឿនឆ្លងកាត់ តើលោកអ្នកត្រូវតែធ្វើដូចម្តេច ： （1） បើកបរឆ្លងកាត់តាមម៉ូតូខាងមុខភ្លាម （2）<br>បញ្ឈប់ម៉ូតូ ពិនិត្យសងខាងបញ្ជាក់ថា គ្មានគ្រោះថ្នាក់ទេ ទើបឆ្លងកាត់ពីក្រោមរបង （3） បញ្ឈប់ម៉ូតូ<br>ចាំរថភ្លើងឆ្លងកាត់ របងបានលើកឡើង ទើបឆ្លងកាត់ ។ | 11 |
| 076 | 1 | គ្រោះថ្នាក់ចរាចរណ៍ភាគច្រើនបណ្តាលមកពីមូលហេតុមនុស្ស មិនគោរពតាមក្បួនខ្នាតចរាចរណ៍<br>ការធ្វេសប្រហែសជាដើម ដូច្នេះ ត្រូវតែបង្កើនចំណែកណាទុកជាមុន : （1）ការអប់រំក្បួនខ្នាតចរាចរណ៍<br>បណ្តុះបណ្តាលសីលធម៌បើកបរ （2）លើកដំឡើងបច្ចេកទេសបើកបរ （3）អប់រំមធ្យោបាយថែទាំយានយន្ត។ | 11 |
| 077 | 3 | ការបើកយានយន្តក្រោយពេលផឹកស្រា<br>នឹងកើតឡើង 「 លទ្ធផលក្នុងរូងក្នុងដីចំពោះចក្ខុវិស័យ 」 ទៅលើអ្នកបើកបរ<br>អ្នកបើកបរហាកដូចជាបើកយានយន្តក្នុងរូងក្នុងដី នៅខាងមុខមានពន្លឺ តែនៅជុំវិញងងឹត ដូច្នេះ<br>បើកបរយានយន្តក្រោយពីផឹកស្រា : （1）ចក្ខុវិស័យមិនប្រែប្រួលទេ<br>（2）ចក្ខុវិស័យក្លាយកាន់តែធំ។（3）ចក្ខុវិស័យក្លាយកាន់តែចង្អៀត ។ | 11 |

| | | | |
|---|---|---|---|
| 078 | 1 | កាលណាបើកបរលើផ្លូវ ការបង់ចោលវត្ថុ កន្ទុយបារីឬ វត្ថុសម្រាប់បង្កាត់ភ្លើងដោយផ្តេសផ្តាស :（1 ）នេះជាអំពើគ្រោះថ្នាក់ហើយគ្មានសីលធម៌（2）ឱ្យតែខ្ញុំសប្បាយចិត្ត ក៏អាចធ្វើបាន （3）អាចចៀសវាងយានយន្តក្លាយកខ្វក់ ត្រូវតែបង់ចោល។ | 11 |
| 079 | 2 | កាលណាកើតឡើងគ្រោះថ្នាក់ចរាចរណ៍ សាមីខ្លួនត្រូវតែខិតខំស្វែងរក : （1）ញាតិសន្តានមិត្តភ័ក្តល្អ（2）សាក្សីបានមើលឃើញ（3）អ្នកច្បាប់ ដើម្បីជួយវិនិច្ឆ័យរឿងក្តីឱ្យច្បាស់។ | 11 |
| 080 | 3 | ក្នុងគ្រោះថ្នាក់រថយន្ត សាមីខ្លួនបានស្លាប់ឬពិការទាំងស្រុង ការធានារ៉ាប់រងដោយបង្ខំលើយានយន្តនឹងសងសំណងប្រាក់ជាអតិបរមា（1）100,000យ៉ន់（2） 200,000យ៉ន់（3） 2,000,000យ៉ន់។ | 12 |
| 081 | 1 | ក្នុងការណីអ្នកបើកបរបើករថយន្តលើសពីល្បឿនជាអតិបរមា ដែលបានកំណត់ ត្រូវដាក់ទ័ណ្ឌកម្ម ： （1） ពិន័យប្រាក់ ហើយកត់ត្រាពិន្ទុពិន័យ（2） ដកហូតប័ណ្ណអនុញ្ញាតរថយន្តបើកបរ（3） ដកហូតប័ណ្ណបើកបរ | 12 |

| 題號 | 答案 | 題　　目 | 分類編號 |
|---|---|---|---|
| 082 | 3 | អ្នកជិះម៉ូតូចតម៉ូតូនឹងកង់ក្រោយ បើកបរដោយខ្សែរបត់ ឬរុះបំផ្លាញឧបករណ៍បំបាត់សូរសំឡេង បណ្តាលឱ្យបានបង្កឧប្បត្តិហេតុ នឹងត្រូវផ្តន្ទាទោស ： （1） ឱ្យដំបូន្មាន（2） ពិន័យប្រាក់ ហើយដកយកម៉ូតូ（3） ពិន័យប្រាក់ ហើយដកហូតប័ណ្ណបើកបររបស់គាត់ ។ | 12 |
| 083 | 2 | ពីព្រោះបានល្មើសកំណត់ចរាចរណ៍ អ្នកបើកបរត្រូវពិន័យប្រាក់ ហើយកត់ពិន្ទុពិន័យ នៅពេលក្រោយ អ្នកបើកបរត្រូវតែ（1） មិនអើពើអ្វីទេ（2） ប្រុងប្រយ័ត្នបើកបររថយន្ត ចៀសវាងកុំឱ្យល្មើសកំណត់ចរាចរណ៍ទេ（3） ចាប់តាំងពីថ្ងៃនោះ លែងបើកបររថយន្តទេ ។ | 12 |
| 084 | 3 | អ្នកបើកបរដែលមិនគោរពតាមការបញ្ជារបស់ប៉ូលិស ចរាចរណ៍ ឬបុគ្គលិកដែលបំពេញបេសកកម្មចរាចរណ៍តាមបទបញ្ញត្តិ ត្រូវផ្តន្ទាទោស ： （1） ដកហូតប័ណ្ណបើកបរអស់រយៈពេល ១ ខែ（2） ដកហូតប័ណ្ណបើកបរអស់រយៈពេល ២ ខែ （3） ពិន័យប្រាក់ ហើយកត់ត្រាពិន្ទុពិន័យ ។ | 12 |
| 085 | 2 | ក្រោយបានទទួលផ្លាកលេខ បើមិនបាច់ប្រើប្រាស់សិន ： （1） អាចខ្ចីឱ្យរថយន្តឯទៀតពាក់ប្រើប្រាស់បាន （2） ត្រូវស្នើសុំអង្គការត្រួតត្រាផ្លូវថ្នល់តាមតំបន់ ដូកយកនិងលុបចោលផ្លាកលេខនេះ（3） រក្សាទុកដោយខ្លួនឯង ។ | 12 |
| 086 | 1 | អ្នកទទួលបានប័ណ្ណអនុញ្ញាតជិះម៉ូតូធំធ្ងន់ អាចបើកបរ ： （1） ម៉ូតូស្រាល（2） រថយន្តស្រាលដឹកទំនិញ（3） រថយន្តដឹកអ្នកដំណើរស្រាល ។ | 12 |

| | | | |
|---|---|---|---|
| 087 | 2 | អ្នកបើកបរយល់ព្រមអ្នកដែលគ្មានប័ណ្ណបើកបរទៅបើកបរយានយន្តរបស់ខ្លួន នឹងដាក់ទណ្ឌកម្ម ដកយកប័ណ្ណបើកបរជាបណ្ដោះអាសន្ន (1)២ខែ (2)៣ខែ (3)៤ខែ។ | 12 |
| 088 | 3 | ក្នុងករណីអ្នកបើកបរនិយាយកំហុកថា ប័ណ្ណបើកបរបាត់បង់ហើយ ស្នើសុំអង្គការត្រួតត្រាផ្លូវថ្នល់ចាត់ការចែកប័ណ្ណថ្មីមួយទៀត ហើយប្រើប្រាស់ប័ណ្ណថ្មីនេះ អ្នកបើកបរនោះត្រូវផ្ដន្ទាទោស" (1) ពិន័យប្រាក់ (2) ដកហូតប័ណ្ណបើកបរ (3) ពិន័យប្រាក់ ហើយដកហូតប័ណ្ណបើកបរដែលបញ្ឆោតទទួលបាន ។ | 12 |
| 089 | 2 | ម៉ូតូអាច : (1) អាចពាក់ផ្លាកលេខម៉ូតូឯទៀតខ្ចីពីគេបានសំរាប់បើកបរ (2) ពុំអាចពាក់ផ្លាកលេខម៉ូតូឯទៀតខ្ចីពីគេទេ (3) អាចពាក់ផ្លាកលេខដែលធ្វើដោយខ្លួនឯងបានសំរាប់បើកបរ ។ | 12 |
| 090 | 3 | អ្នកបើកបរយានយន្តឆ្លងកាត់ផ្លូវសំរាប់អ្នកដំណើរឆ្លងកាត់ ឬទ្ធឆ្លងកាត់ផ្លូវសំរាប់អ្នកដំណើរឆ្លងកាត់ តែមិនតាមកំណត់ឱ្យអ្នកដំណើរដើរមុន ដូច្នេះ បណ្ដាលមនុស្សរបួសឬស្លាប់ តាមច្បាប់ត្រូវមានកាតព្វកិច្ចឧក្រិដ្ឋកម្ម ហើយត្រូវបន្ថែមទោស (1)១ដង (2)២ដង (3)១ភាគ២។ | 12 |
| 091 | 2 | កាលណាឮភេរវសញ្ញានៃរថយន្តពន្លត់អគ្គិភ័យ រថយន្តប៉ូលីស រថយន្តសង្គ្រោះ និងរថយន្តសង្គ្រោះគ្រោះថ្នាក់វិស្វកម្ម រថយន្តឆ្លើយតបនឹងគ្រោះថ្នាក់ដោយសារធាតុគីមីពុល អ្នកដែលមិនចៀសវាង នឹង ១១ចដកយកប័ណ្ណបើកបរ៣ខែ ១២ច ពិន័យប្រាក់ និងដកហូតប័ណ្ណបើកបរ ១៣ចពិន័យប្រាក់។ | 12 |

| 題號 | 答案 | 題　　目 | 分類編號 |
|---|---|---|---|
| 092 | 3 | ក្នុងករណីអ្នកជិះម៉ូតូបើកបរឆ្លងកាត់មាត់ផ្លូវបំបែកដែលមានសញ្ញាភ្លើងគ្រប់គ្រងចរាចរណ៍ ភ្លើងក្រហមបានបើកហើយអ្នកជិះម៉ូតូនៅតែបើកបរទៅមុខ ក្រៅពីពិន័យប្រាក់ ហើយនឹងកត់ត្រាពិន្ទុពិន័យ" (1) ១ ពិន្ទុ (2) ២ ពិន្ទុ (3) ៣ ពិន្ទុ។ | 12 |
| 093 | 3 | អ្នកខុសច្បាប់ស្ដីពីការគ្រប់គ្រងកិច្ចការចរាចរណ៍ផ្លូវថ្នល់ ក្រោយពីទទួលលិខិតជូនដំណឹងស្ដីពីរឿងល្មើសកំណត់នៃការគ្រប់គ្រងចរាចរណ៍ មិនបាច់កាត់ក្ដីក៏ត្រូវតាមកំណត់ស្តង់ដារពិន័យប្រាក់នៃខទី៣ ប្រការទី៩២ ទៅកន្លែងដែលកំណត់បង់ប្រាក់ ក្នុងប៉ុន្មានថ្ងៃ? (1)ក្នុង១0ថ្ងៃ (2)ក្នុង២0ថ្ងៃ (3)ក្នុង៣0ថ្ងៃ។ | 12 |
| 094 | 1 | ក្នុងករណីអ្នកបើកបររថយន្តបុកដល់ប៉ូលិសដែលកំពុងបំពេញបេសសកម្មចរាចរណ៍ នឹងត្រូវផ្ដន្ទាទោស" (1) ដូកហូតប័ណ្ណបើកបរ ហើយពិន័យប្រាក់ (2) ដកូ យកប័ណ្ណបើកបរ ហើយពិន័យប្រាក់ (3) ពិន័យប្រាក់តាមកំរិតបំផុត | 12 |
| 095 | 1 | នៅពេលប័ណ្ណបើកបរបានខូចខាតមិនងាយស្គាល់ទេ អ្នកបើកបរត្រូវតែ" (1) ស្នើសុំផ្លាស់ប្ដូរប័ណ្ណថ្មីមួយ (2) ចូលរួមការប្រឡងដើម្បីទទួលប័ណ្ណថ្មីមួយ (3) នៅអាចបើកបររថយន្តបាន ។ | 12 |

| | | | |
|---|---|---|---|
| 096 | 3 | អ្នកបើកបរយានយន្តហួសល្បឿនកំណត់ នឹងដាក់ទណ្ឌកម្ម（1）ពិន័យប្រាក់（2）ពិន័យប្រាក់<br>និងដកយកប័ណ្ណបើកបរ១ខែ（3）ពិន័យប្រាក់ និងកត់ត្រាពិន្ទុល្មើសច្បាប់១ពិន្ទុ។ | 12 |
| 097 | 1 | លើផ្លូវសំរាប់អ្នកដំណើរឆ្លងកាត់ កាលណាមានអ្នកដំណើរដើរកាត់ ត្រូវតែ（1）បញ្ឈប់យានយន្ត<br>ឱ្យអ្នកដំណើរឆ្លងកាត់ជាមុន（2）ចុចស៊ីផ្លេ សូមអ្នកដំណើរចៀសផុត（3）បង្កើនល្បឿនបើកបរ។ | 12 |
| 098 | 2 | ក្នុងករណីដែលអ្នកបើកបរផឹកស្រាស្រវឹង ភាពខាប់ស្រាក្នុងឈាមបានលើសពីស្តង់ដារកំណត់<br>ហើយបង្កបង្កើត ឧប្បត្តិហេតុចរាចរណ៍ បណ្តាលឱ្យមនុស្សរងរបួស ឬស្លាប់<br>តាមបទបញ្ញត្តិដាក់ទ័ណ្ឌកម្មនៃការគ្រប់គ្រងចរាចរណ៏ផ្លូវ ថ្នល់អ្នកបើកបរត្រូវផ្តន្ទាទោស៍（1）<br>ដកយកប័ណ្ណបើកបរ （2） ពិន័យប្រាក់ ដកហូតប័ណ្ណបើកបរ<br>ហើយមិនអនុញ្ញាតចូលរួមការប្រឡងនិងទទួលប័ណ្ណអស់មួយជីវិត（ប៉ុន្តែអ្នកដែលពេញលក្ខណៈពិសេស<br>ហើយរយៈពេលដកហូតប័ណ្ណអនុញ្ញាត បើកបរបានហួសពេលកំណត់ហើយ មិនចាំបាច់គោរពតាមកំណត់នេះទេ<br>）（3） ពិន័យប្រាក់ ។ | 12 |
| 099 | 1 | ក្នុងករណីឧបករណ៏បំបាត់សូរសំឡេងបានខុសហើយ រងី អ្នកបើកបរមិនជួសជុលនៅតែបើកបរទៅផ្លូវ តាមបទ<br>បញ្ញត្តិដាក់ទ័ណ្ឌកម្មនៃការគ្រប់គ្រងចរាចរណ៏ផ្លូវថ្នល់ អ្នកបើកបរ ត្រូវផ្តន្ទាទោស៍（1） ពិន័យប្រាក់<br>ហើយបញ្ជាគេកែប្រែ （2） ការទិទៀនពីប៉ូលិសចរាចរណ៏（3） ដកយកផ្លាកលេខ ។ | 12 |
| 100 | 1 | ក្នុងករណីម៉ូតូបើកបរលើសពីល្បឿនកំណត់ តាមបទបញ្ញត្តិ ដាក់ទ័ណ្ឌកម្មនៃការគ្រប់គ្រងចរាចរណ៏ផ្លូវថ្នល់<br>អ្នកបើកបរត្រូវផ្តន្ទាទោស៍ （1） ពិន័យប្រាក់ ហើយកត់ត្រាពិន្ទុពិន័យ （2） ដកយកផ្លាកលេខម៉ូតូ（3）<br>ដកយកប័ណ្ណបើកបរ ។ | 12 |
| 101 | 3 | ក្នុងករណីអ្នកបើកបរខ្ចីប័ណ្ណបើកបររបស់ខ្លួនឯងឱ្យគេបើកបរ ត្រូវផ្តន្ទាទោស<br>ដកយកប័ណ្ណបើកបរអស់រយៈពេល :（1） ១ ខែ （2） ២ ខែ （3） ៣ ខែ ។ | 12 |

| 題號 | 答案 | 題　目 | 分類編號 |
|---|---|---|---|
| 102 | 1 | អ្នកជិះម៉ូតូបើកបរដោយខ្សែរបត់ ឬចតម៉ូតូនឹងកង់ក្រោយ ឬតាមវិធីគ្រោះថ្នាក់ផ្សេងទៀត<br>បណ្តាលឱ្យបានបង្ក ឧប្បត្តិហេតុ នឹងត្រូវផ្តន្ទាទោស ： （1） ពិន័យប្រាក់<br>ហើយដកហូតប័ណ្ណបើកបររបស់គាត់ ។（2） ដកយកប័ណ្ណបើកបរ（3） ពិន័យប្រាក់ | 12 |
| 103 | 3 | អ្នកណាប្រើប្រាស់រថយន្តប្រព្រឹត្តបទឧក្រិដ្ឋ បានត្រូវកាត់ទោសជាពេលកំណត់ ក្រៅពីដកហូតប័ណ្ណបើកបរ ：<br>（1） មិនអនុញ្ញាតចូលរួមការប្រឡងនិងទទួលប័ណ្ណអស់រយៈពេល ១ ឆ្នាំ （2）<br>មិនអនុញ្ញាតចូលរួមការប្រឡងនិងទទួលប័ណ្ណអស់រយៈពេល ៣ ឆ្នាំ（3）<br>មិនអនុញ្ញាតចូលរួមការប្រឡងនិងទទួលប័ណ្ណអស់មួយជីវិត ។（ប៉ុន្តែអ្នកដែលពេញលក្ខណៈពិសេស<br>ហើយរយៈពេលដកហូតប័ណ្ណ អនុញ្ញាតបើកបរបានហួសពេលកំណត់ហើយ<br>មិនចាំបាច់គោរពតាមកំណត់នេះទេ） | 12 |

| | | | |
|---|---|---|---|
| 104 | 1 | អ្នកបើកបរដែលល្មើសកំណត់សន្តិសុខចរាចរណ៍ផ្លូវថ្នល់ ហើយបង្កហេតុបណ្ដាលមនុស្សរងរបួសធ្ងន់ ត្រូវដកហូតប័ណ្ណអនុញ្ញាតបើកបររបស់គាត់ អស់រយៈពេល ៖ (1) ៣ ខែ ដល់ ៦ ខែ (2) ១ ខែ ដល់ ២ ខែ (3) ២ ខែ ដល់ ៤ ខែ ។ | 12 |
| 105 | 1 | បើសិនអ្នកបើកយានយន្តបង្កគ្រោះថ្នាក់ បណ្ដាលឱ្យមនុស្សរងរបួសធ្ងន់ឬស្លាប់ ត្រូវដោះស្រាយភ្លាម ហើយរបាយការណ៍ទៅអង្គការប៉ូលីស មិនត្រូវគេចរត់ អ្នកល្មើស នឹងដាក់ទណ្ឌកម្ម (1)ដកហូតប័ណ្ណបើកបរ ហើយហាមឃាត់ចូលការប្រឡងនិងទទួលប័ណ្ណបើកបរអស់មួយជីវិត(ប៉ុន្តែអ្នកដែលពេញលក្ខណៈពិសេស ហើយទណ្ឌកម្មលើការដកហូតប័ណ្ណបើកបរបានហួសពេលកំណត់ហើយ គ្មានកំហិតទេ) (2)ពិន័យប្រាក់ (3)ដកយកប័ណ្ណបើកបរ១ឆ្នាំ។ | 12 |
| 106 | 1 | អ្នកបើកម៉ូតូត្រូវបានឃាត់ខ្លួនដោយសារពេលកំពុងបើកបរ ប្រើទូរស័ព្ទដៃ កំព្យូទ័រ ឬប្រើរបស់បែបនេះដើម្បីទំនាក់ទំនងគ្នា ឬធ្វើសកម្មភាពផ្សេងៗដែលនាំអោយមានគ្រោះថ្នាក់ចរាចរណ៍ តើត្រូវទទួលការពិន័យប៉ុន្មាន? (1) ១000 ដុល្លារតៃវ៉ាន់ (2) ១៥00 ដុល្លារតៃវ៉ាន (3) ២000ដុល្លារតៃវ៉ាន់ ។ | 12 |
| 108 | 2 | ក្នុងអំឡុងពេល៦ខែ អ្នកបើកបរត្រូវកត់ត្រាពិន្ទុល្មើសច្បាប់សរុបលើសពី៦ពិន្ទុ នឹងដកយកប័ណ្ណបើកបរអស់រយៈពេល (1)៦ខែ (2)១ខែ (3)១ឆ្នាំ។ | 12 |
| 109 | 3 | អ្នកបើកបរត្រូវកត់ត្រាពិន្ទុដោយសារល្មើសច្បាប់ ក្នុង១ឆ្នាំ ត្រូវដកយកប័ណ្ណបើកបរ២ដង បើសិនត្រូវកត់ត្រាពិន្ទុល្មើសច្បាប់ទៀត នឹងដាក់ទណ្ឌកម្ម (1)ពិន័យប្រាក់ (2)ដកយកប័ណ្ណបើកបរ១ខែ (3)ដកហូតប័ណ្ណបើកបរ ។ | 12 |
| 110 | 1 | កំណត់ពេលសំរាប់ចតរថយន្តជាបណ្ដោះអាសន្ន គឺ (1) ពុំអាចលើសពី ៣ នាទី ហើយត្រូវតែត្រៀមបើកទៅ (2) ពុំអាចលើសពី ១0 នាទី អ្នកបើកបរអាចចាកចេញពីរថយន្តបាន (3) ឱ្យតែមិនលើសពី ៥ នាទី កចំានដែរ ។ | 12 |

| 題號 | 答案 | 題　　目 | 分類編號 |
|---|---|---|---|
| 111 | 3 | អ្នកជិះម៉ូតូមើលឃើញភ្លើងក្រហមបើកហើយ មិនអើពើ នៅតែបើកទៅមុខ នឹងត្រូវផ្តន្ទាទោស" (1) ពិន័យប្រាក់ ១,២00 ដល់ ៣,៦00 ដុល្លារថ្មីតៃវ៉ាន់ ។ (2) ដកយកប័ណ្ណបើកបរអស់រយៈពេល ១ ខែ ។ (3) ពិន័យប្រាក់ ១,៨00 ដល់ ៥,៤00 ដុល្លា រថ្មីតៃវ៉ាន ហើយកត់ពិន្ទុពិន័យ ៣ ពិន្ទុ ។ | 12 |
| 112 | 2 | នៅពេលជិះម៉ូតូផ្ទុកមនុស្ស ៖ (1) អាចទ្រេតអង្គុយ (2) ពុំអាចទ្រេតអង្គុយទេ ដើម្បីធានាសន្តិសុខ (3) គ្មានកំណត់ទេ ។ | 12 |

| 題號 | 答案 | 題　目 | 分類編號 |
|---|---|---|---|
| 113 | 2 | នៅពេលរថយន្តខាងក្រោយមានបំណងចង់បើកផុតរថយន្តខាងមុខ អ្នកបើកបរត្រូវតែ ៖ （1） បើកផុតរថយន្តខាងមុខពីខាងស្តាំ （2） បើកផុតរថយន្តខាងមុខពីខាងឆ្វេង （3） អាចបើកផុតពីសងខាងនៃរថយន្តខាងមុខ ។ | 12 |
| 114 | 2 | ប័ណ្ណបើកបរដែលបានលុបចោលពីបញ្ជី ត្រូវតែ （1） រក្សាទុកដោយខ្លួនឯង （2） ប្រគល់ឱ្យអង្គការត្រួតត្រាផ្លូវថ្នល់（3） បន្តប្រើប្រាស់ ។ | 12 |
| 115 | 1 | នៅពេលបើកបររថយន្តជិតដល់ផ្លូវសំរាប់អ្នកដំណើរឆ្លងកាត់ អ្នកបើកបរត្រូវតែ ៖ （1） ពន្យឺតល្បឿនបើកមួយៗ នៅពេលជួបប្រទះអ្នកដំណើរឆ្លងកាត់ផ្លូវ ត្រូវឈប់រថយន្តជាបណ្តោះអាសន្ន ឱ្យអ្នកដំណើរ ដើរទៅសិន（2） ចុចស៊ីផ្លេឆ្លងកាត់ （3） បង្កើនល្បឿនឆ្លងកាត់ ។ | 12 |
| 116 | 2 | នៅខាងមុខមាត់ចេញចូលនៃកន្លែងសាធារណៈនិងស្ថានីយរថយន្ត（1） អាចចតរថយន្ត（2） ពុំអាចចតរថយន្ត（3） គ្មានកំណត់ទេ ។ | 12 |
| 117 | 1 | នៅលើកៅអីនៃខាងក្រោយរបស់អ្នកជិះម៉ូតូធំធ្ងន់ អាចដឹកមនុស្សប៉ុន្មាននាក់ （1） ១ នាក់ （2） ២ នាក់（3） ៣ នាក់ ។ | 12 |
| 118 | 2 | អ្នកជិះម៉ូតូបើកបរនៅលើផ្លូវមានទិសផ្ទុយគ្នា ហើយបានចែកខ្សែផ្លូវលឿននិងខ្សែផ្លូវយឺត ប៉ុន្តែគ្មានសញ្ញានិងខ្សែបន្ទាត់ចរាចរណ៍ ត្រូវតែ ៖ （1）បើកបរនៅខ្សែផ្លូវខាងក្នុងបំផុត（2）បើកបរនៅខ្សែផ្លូវខាងក្រៅបំផុតនិងខ្សែផ្លូវយឺត（3）គ្មានកំណត់ទេ ។ | 12 |
| 119 | 1 | ក្នុងករណីរថយន្តជួបប្រទះនៅពេលយប់ អ្នកបើកបរត្រូវតែ ៖ （1）បើកភ្លើងបំភ្លឺចម្ងាយជិត（2）បើកភ្លើងបំភ្លឺចម្ងាយឆ្ងាយ （3）គ្មានកំណត់ទេ ។ | 12 |
| 120 | 2 | នៅពេលម៉ូតូដឹកទំនិញ កំពស់ទំនិញមិនអនុញ្ញាតលើសពីចំណែកណារបស់អ្នកបើកបរទេ ៖ （1） ក្បាល（2） ស្មា（3） ចង្កេះ | 12 |
| 121 | 1 | ទទឹងនៃវត្ថុផ្ទុកលើម៉ូតូ មិនអនុញ្ញាតហួសពីជាយដងដៃនៃម៉ូតូ（1）១0សង្ទីម៉ែត្រ（2）២ម៉ែត្រ（3）១ម៉ែត្រកន្លះ។ | 12 |
| 122 | 1 | មុនពេលបើកបររថយន្ត អ្នកជិះម៉ូតូត្រូវតែ ៖ （1） ចាំបាច់ត្រួតពនិត្យគ្រឿងបន្លាស់គ្រប់ផ្នែកនៃម៉ូតូ（2） ម៉ូតូមានគុណភាពល្អប្រសើរ មិនចាំបាច់ត្រួតពិនិត្យទេ（3） គ្មានកំណត់ទេ ។ | 12 |

| | | | |
|---|---|---|---|
| 123 | 2 | នៅពេលម៉ូតូធំធ្ងន់ដឹកវត្ថុ ទម្ងន់វត្ថុមិនអនុញ្ញាតលើសពី ៖ （1）៥0 គីឡូក្រាម（2）៨0 គីឡូក្រាម（3）៩0 គីឡូក្រាម ។ | 12 |
| 124 | 3 | ល្បឿនបើកបរម៉ូតូត្រូវតែគោរពតាមកំណត់នៃសញ្ញាកំរិតល្បឿនឬសញ្ញាបន្ទាត់ បើសិនគ្មានសញ្ញាកំរិតល្បឿនឬសញ្ញាបន្ទាត់ នៅផ្លូវមិនទាន់គូសខ្សែផ្លូវបើកបរ ខ្សែបែងចែកទិសដៅបើកបរ ល្បឿនបើកបរក្នុងមួយម៉ោង（1）មិនអនុញ្ញាតហួសពី២0គីឡូម៉ែត្រ（2）មិនអនុញ្ញាតហួសពី៣0គីឡូម៉ែត្រ（3）មិនអនុញ្ញាតហួសពី៤0គីឡូម៉ែត្រ ។ | 12 |
| 125 | 2 | នៅពេលជិះម៉ូតូ ៖ （1） មិនចាំបាច់ពាក់មួកការពារសន្តិសុខទេ （2） ចាំបាច់ពាក់មួកការពារសន្តិសុខដើម្បីធានាសន្តិសុខ （3） ច្បាប់បានកំណត់ថា មិនចាំបាច់ពាក់មួកការពារសន្តិសុខទេ ។ | 12 |
| 126 | 1 | ល្បឿនបើកបរម៉ូតូត្រូវតែគោរពតាមកំណត់នៃសញ្ញាកំរិតល្បឿនឬសញ្ញាបន្ទាត់ បើសិនគ្មានសញ្ញាកំរិតល្បឿនឬសញ្ញាបន្ទាត់ ល្បឿនបើកបរក្នុងមួយម៉ោងមិនអនុញ្ញាតហួសពី（1）៥0គីឡូម៉ែត្រ（2）៤0គីឡូម៉ែត្រ（3）៣0គីឡូម៉ែត្រ ។ | 12 |
| 127 | 1 | នៅពេលយប់ អ្នកជិះម៉ូតូដល់កន្លែងមានស្ថានភាពបំភ្លឺល្អប្រសើរនៅក្នុងតំបន់ទីក្រុង ត្រូវតែ ៖ （1） បើកភ្លើងបំភ្លឺចម្ងាយជិត （2） អាចបើកភ្លើងបំភ្លឺចម្ងាយឆ្ងាយ （3） អាចបិទភ្លើងបាន ។ | 12 |
| 128 | 1 | មុនពេលបើកបរម៉ូតូ អ្នកជិះត្រូវតែ ៖ （1） ត្រៀមយកឧបករណ៍ម៉ូតូឱ្យគ្រប់គ្រាន់（2） ម៉ូតូស្រួលមិនចាំបាច់យកទេ （3） គ្មានកំណត់ទេ ។ | 12 |
| 129 | 1 | នៅពេលម៉ូតូពីរគ្រឿងបើកស្របទិសគ្នា ម៉ូតូខាងមុខនិងម៉ូតូខាងក្រោយត្រូវតែ ៖ （1） ធានាទុកចម្ងាយសមល្មម ដើម្បីបញ្ឈប់ម៉ូតូនៅគ្រប់ពេលវេលា （2） មិនចាំបាច់ធានាទុកចម្ងាយអ្វីទេ （3） ត្រូវតែបើកបរទៅមុខទន្ទឹមគ្នា | 12 |
| 130 | 2 | នៅពេលបើកបររថយន្តចុះផ្លូវជំរាល ៖ （1） អាចបិទម៉ាស៊ីនភ្លើងរថយន្ត បើកថ្លាក់ទទេប្រមៀល （2） ពុំអាចបិទម៉ាស៊ីនភ្លើងរថយន្ត បើកថ្នាក់ទទេប្រមៀលទេ（3） គ្មានកំណត់ទេ ។ | 12 |
| 131 | 2 | ក្នុងករណីភ្លើងរថយន្តគ្រប់ប្រភេទបានខូចខាត ឬមិនគ្រប់គ្រាន់ទេ ៖ （1） មិនប៉ះពាល់ដល់សន្តិសុខបើកបររថយន្តទេ （2） ប៉ះពាល់ដល់សន្តិសុខក្នុងការបើកបររថយន្តយ៉ាងខ្លាំង（3） បើកបររថយន្តតាមពេលធម្មតា ។ | 12 |
| 132 | 3 | លើផ្លូវដែកកាត់ផ្លូវគោក មាត់ផ្លូវខ្វែង ផ្លូវល្បឿនលឿន ផ្លូវសំរាប់អ្នកដំណើរឆ្លងកាត់（1）អាចចតយានយន្តបាន（2）អាចចតយានយន្តជាបណ្តោះអាសន្ន（3）មិនអាចចតយានយន្តជាបណ្តោះអាសន្ន ។ | 12 |

| | | | |
|---|---|---|---|
| 133 | 1 | អ្នកជិះម៉ូតូបើកបរនៅលើផ្លូវឯកទិសដែលមិនចែកខ្សែផ្លូវលឿននិងខ្សែផ្លូវយឺត ត្រូវតែ（1 ）បើកបរនៅខ្សែផ្លូវខាងឆ្វេងបំផុតនិងខាងស្តាំបំផុត（2） បើកបរនៅខ្សែផ្លូវខាងស្តាំបំផុត（3） បើកបរនៅខ្សែផ្លូវណាក៏បានដែរ ។ | 12 |

| 題號 | 答案 | 題　　目 | 分類編號 |
|---|---|---|---|
| 134 | 2 | នៅពេលម៉ូតូបើកនៅលើផ្លូវ ៖ （1） សញ្ញាចរាចរណ៍ពុំអាចកំរិតម៉ូតូទេ （2） ត្រូវតែគោរពកំណត់នៃសញ្ញាខ្សែបន្ទាត់ ភ្លើងចរាចរណ៍（3） សញ្ញាគ្រប់ប្រភេទគ្មានពាក់ព័ន្ធនឹងម៉ូតូទេ មិនចាំបាច់អើពើទេ។ | 12 |
| 135 | 2 | នៅផ្លូវសំរាប់អ្នកដំណើរឆ្លងកាត់ ៖ （1） អាចចតរថយន្ត （2） ពុំអាចចតរថយន្តជាបណ្តោះអាសន្នទេ （3） គ្មានកំណត់ទេ ។ | 12 |
| 136 | 1 | ល្បឿនបើកបរម៉ូតូត្រូវតែគោរពតាមកំណត់នៃសញ្ញាកំរិតល្បឿនឬសញ្ញាបន្ទាត់<br>បើសិនគ្មានសញ្ញាកំរិតល្បឿនឬសញ្ញាបន្ទាត់<br>នៅផ្លូវសំរាប់រថយន្តល្បឿនយឺតដែលមានខ្សែបែងចែកខ្សែផ្លូវល្បឿនលឿននិងខ្សែផ្លូវល្បឿនយឺត<br>ល្បឿនបើកបរក្នុងមួយម៉ោងមិនអនុញ្ញាតហួសពី（1）៤0គីឡូម៉ែត្រ（2）៥0គីឡូម៉ែត្រ（3）៦0គីឡូម៉ែត្រ។ | 12 |
| 137 | 3 | រយៈពេលចុចស៊ីផ្លេម្តងត្រូវតែ （1） មិនហួសពី ២ វិនាទី （2） មិនហួសពី ១ វិនាទី （3） មិនហួសពី កន្លះវិនាទី ។ | 12 |
| 138 | 1 | អ្នកបើកបរម៉ូតូមានជម្ងឺរំខានដល់សុវត្ថិភាពបើកបរ ឬក្រោយពីផឹកស្រាហើយខ្យល់បញ្ចេញដង្ហើមរបស់គាត់មានភាពខាប់អាកុល0 ។១៥មីល្លីក្រាមក្នុងមួយលីត្រ（1 ）មិនអនុញ្ញាតបើកម៉ូតូ（2）អាចបើកបរតាមធម្មតា（3）បើកម៉ូតូកុំលឿនពេក។ | 12 |
| 139 | 3 | កាលណាឮភេរវសញ្ញានៃរថយន្តពន្លត់អគ្គិភ័យ រថយន្តប៉ូលីស រថយន្តសង្គ្រោះ<br>និងរថយន្តសង្គ្រោះគ្រោះថ្នាក់វិស្វកម្ម រថយន្តឆ្លើយតបនឹងគ្រោះថ្នាក់ដោយសារធាតុគីមីពុល<br>មិនថាមកពីទិសដៅណា ត្រូវតែ ១១ចមិនបាច់ចៀសផុតឱ្យគេបើកមុន ១២ចឱ្យតែមិនឆ្លងខ្សែបើកបរ<br>ក៏មិនបាច់ចៀសផុតទេ ១៣ចសុទ្ធតែត្រូវចៀសផុតភ្លាម ឱ្យគេបើកមុន<br>ហើយកុំតាមដាននៅខាងក្រោយបើកលឿន។ | 12 |
| 140 | 2 | នៅពេលជិះម៉ូតូ គ្រឿងបរិក្ខារការពាររាងកាយសំខាន់ជាងគេ គឺ ៖ （1） ខ្សែក្រវាត់ធំ（2） មួកការពារសន្តិសុខ（3） វ៉ែនតាការពារខ្យល់ ។ | 12 |
| 141 | 1 | មុននឹងចាប់ផ្តើមបើកម៉ូតូ（1）ត្រូវបើកភ្លើងបង្ហាញទិសដៅ ប្រុងប្រយ័ត្នខាងមុខ ខាងក្រោយ ខាងស្តាំខាងឆ្វេងមានឧបសគ្គឬយានយន្ត មនុស្សឬទេ（2）មើលម្ខាងមានយានយន្តឆ្លងកាត់ឬទេ<br>（3）មើលផ្ទៃផ្លូវខាងមុខឱ្យច្បាស់លាស់។ | 12 |

| | | | |
|---|---|---|---|
| 142 | 1 | ក្នុងករណីម៉ូតូបានដឹកទំនិញ ប្រវែងទំនិញបានកំណត់ថា ចាប់ពីកង់គិតទៅ មិនអាចលើសពី ៖ （1） កន្លះម៉ែត្រ （2） ១ ម៉ែត្រ （3） ៣ ម៉ែត្រ ។ | 12 |
| 143 | 2 | បើគ្មានការបញ្ជានៃសញ្ញាឬសញ្ញាបន្ទាត់ ម៉ូតូបើកលើផ្លូវដែលមិនបែងចែកផ្លូវល្បឿនលឿននិងផ្លូវល្បឿនយឺត ត្រូវបើកបរ（1）លើខ្សែផ្លូវខាងក្នុង（2）លើផ្លូវទី២នៅខាងក្រៅបំផុត（3）កណ្តាលនៃខ្សែផ្លូវខាងក្នុង។ | 12 |
| 144 | 2 | នៅពេលម៉ូតូស្រាលធម្មតាដឹកវត្ថុ កណំត់ទម្ងន់វត្ថុមិនអនុញ្ញាតលើសពី ៖ （1） ៤0 គីឡូក្រាម（2）៥0 គីឡូក្រាម（3）២0 គីឡូក្រាម ។ | 12 |

| 題號 | 答案 | 題　　目 | 分類編號 |
|---|---|---|---|
| 145 | 1 | ក្នុងករណីដែលអ្នកចូលរួមការប្រឡង ម៉ូតូប្រឡងមិនជាប់ អ្នកនោះស្នើសុំប្រឡងម្តងទៀតថ្ងៃចន្លោះនៃការប្រឡងលើកទីពីរត្រូវពីលើកទីមួយ យ៉ាងហោចណាស់ ៖ （1） ៧ ថ្ងៃ（2） ១៥ ថ្ងៃ （3） ៣0 ថ្ងៃ ។ | 12 |
| 146 | 1 | នៅពេលរថយន្តទាំងពីរបានជួបប្រទះ យ៉ាងហោចណាស់ ចម្ងាយពីគ្នាត្រូវមាន （1） កន្លះម៉ែត្រ （2） ១ ម៉ែត្រ （3） ២ ម៉ែត្រ | 12 |
| 147 | 1 | យានយន្តបើកលើផ្លូវរបត់ ជំរាលចោត ស្ពានចង្អៀត រូងក្រោមដី មាត់ផ្លូវខ្វែងមានសញ្ញាចរាចរណ៍ ឬផ្លូវដែកកាត់ផ្លូវគោក កំណាត់ផ្លូវកំពុងសាងសង់ផ្លូវជាដើម （1）មិនអនុញ្ញាតវ៉ាឡានទេ（2）អាចវ៉ាឡានបាន（3）គ្មានកំណត់ទេ។ | 12 |
| 148 | 1 | ក្នុងករណីដែលអាស័យដ្ឋានរបស់ម្ចាស់ និង អ្នកបើកបរម៉ូតូត្រូវបានផ្លាស់ប្តូរ គេត្រូវតែ :（1） ទៅចុះឈ្មោះប្តូរអាសយដ្ឋាននៅនាយកដ្ឋានចុះបញ្ជីយានយន្ត ។（2）មិនចាំបាច់ស្នើសុំប្តូរអាសយដ្ឋានឡើយ។ （3） ត្រូវទៅចុះឈ្មោះប្តូរអាសយដ្ឋាននៅស្ថានីប៉ូលិសដែលនៅក្បែរនោះ។ | 12 |
| 149 | 2 | នៅពេលម៉ូតូប្រកាសថាគ្មានតំលៃហើយ ត្រូវសរសេរបំពេញលិខិតចុះបញ្ជី ទៅអង្គការត្រួតត្រាផ្លូវថ្នល់ធ្វើការដោះស្រាយការចុះបញ្ជីប្រកាសរថយន្តខូចខាតហើយ ទន្ទឹមនឹងនេះត្រូវតែប្រគល់ ៖ （1） ប័ណ្ណបើកបរ（2） ផ្លាកលេខម៉ូតូនិងប័ណ្ណអនុញ្ញាតម៉ូតូបើកបរ（3） ប័ណ្ណអនុញ្ញាតម៉ូតូបើកបរ ។ | 12 |
| 150 | 1 | ក្នុងករណីដែលម៉ូតូមិនទាន់ចុះបញ្ជីត្រួតពិនិត្យ ហើយមិនទាន់ទទួលបានផ្លាកលេខ អ្នកបើកបរ ៖ （1） មិនអនុញ្ញាតបើកបរទេ （2） អាចបើកបរបាន （3） អាចបើកបរបាននៅជាយក្រុង ។ | 12 |
| 151 | 1 | ការពាក់ផ្លាកលេខរថយន្ត ៖ （1） ត្រូវគោរពតាមកំណត់ ពាក់ផ្លាកលេខនៅកន្លែងដែលបានកំណត់（2） ពាក់ផ្លាកលេខនៅកន្លែងដែលងាយមើលឃើញតាមទំនើងចិត្តក៏បានដែរ （3） គ្មានកំណត់ទេ ។ | 12 |

| | | | |
|---|---|---|---|
| 152 | 3 | ម្ចាស់ម៉ូតូបានដឹងអ្នកបើកបរផឹកស្រាហើយ ប៉ុន្តែមិនហាមឃាត់មិនឱ្យគេបើកបរ ក្រៅពីត្រូវផ្តន្ទាទោសដល់អ្នកបើក បរតាមកំណត់ ហើយនឹងដកយកផ្លាកលេខរថយន្ត អស់រយៈពេល" （1）១ ខែ（2）២ ខែ（3）៣ ខែ ។ | 12 |
| 153 | 3 | តាមកំណត់ធរមាន អ្នកមានប័ណ្ណបើកបរសំរាប់ម៉ូតូធុនធ្ងន់ធម្មតា មិនអនុញ្ញាតបើកបរម៉ូតូមានពីរកង់ដែលមានទំហំស៊ីឡាំង（1）លើសពី៥០ជជ ទាបជាង២៥០ជជ （2）ទាបជាង៥០ជជ（3）លើសពី២៥០ជជ ។ | 12 |
| 154 | 1 | តាមកំណត់ តេស្តលើអ្នកបើកបរយានយន្ត ខ្យល់បញ្ចេញដង្ហើមរបស់គាត់មានភាពខាប់អាកុលក្នុងមួយលីត្រមិនអនុញ្ញាតហួសពី（1）0 ។១៥មីល្លីក្រាម （2）0 ។២៥មីល្លីក្រាម（3）0 ។៥៥មីល្លីក្រាម ។ | 12 |
| 155 | 3 | ក្នុងចំណោមតំបន់ខាងក្រោមនេះ តើតំបន់ណាខ្លះដែលជាតំបន់គ្រោះថ្នាក់ខ្លាំងបំផុត ហើយការបង្អែបង្អង់នៅក្នុងតំបន់ទាំងនេះត្រូវតែចៀសវាង? （1） ផ្លូវដែលមានដុំថ្មតូចៗធ្លាក់មក （2） តំបន់គ្របដណ្តប់ដោយរបាំងការពារថ្មភ្នំ ឬរបាំងការពារផ្លូវមានសភាពខូតខាត និងមានសភាពបត់បែន（3） ទាំងអស់ខាងលើ | 12 |

| 題號 | 答案 | 題　目 | 分類編號 |
|---|---|---|---|
| 156 | 2 | ក្នុងចំណោមលក្ខខណ្ឌអាកាសធាតុខាងក្រោមនេះ តើលក្ខខណ្ឌណាខ្លះដែលគេស្គាល់ថាជាលក្ខខណ្ឌបង្ករអោយមានគ្រោះថ្នាក់ចរាចរណ៍ ហើយអ្នកបើកបរត្រូវតែយល់ដឹងពីវា ? （1） រលករញ្ជួយដី （2） ធ្លាក់ភ្លៀងលាយនិងធ្លាក់ព្រិល （3） សីតុណ្ហភាព | 12 |
| 157 | 3 | ក្នុងចំណោមឥរិយាបថនៃការបើកបរខាងក្រោមនេះ តើឥរិយាបថនៃការបើកបរមួយណាដែលខុស?（1）ការស្តាប់ការផ្សាយរបស់ប៉ូលីសផ្នែកសេវាផ្សាយតាមរលកធាតុអាកាស និងការត្រូវបានជូនដំណឹងអំពីរបាយការណ៍ចុងក្រោយបង្អស់ស្តីពីចរាចរណ៍ ។（2） ប្រសិនបើវង្វេងនៅលើដងផ្លូវ ត្រូវរកមើលសញ្ញាបង្ហាញពីគីឡូម៉ែត្រ ដើម្បីកំណត់ទីតាំងដែលខ្លួនកំពុងស្ថិតនៅ រួចហើយស្វែងរកជំនួយ ។（3） នៅពេលការបើកបរស្ថិតក្នុងការឡោមព័ទ្ធដោយការធ្លាក់ថ្មភ្នំ ជាការល្អ ត្រូវចតយានជំនិះនៅម្ខាងផ្លូវ ហើយពិនិត្យរកមើលថាតើមានតំបន់សុវត្ថិភាពនៅក្បែរៗនោះឬទេ? | 12 |
| 158 | 3 | តើអ្នកបើកបរត្រូវធ្វើបែបណា នៅពេលវង្វេងលើដងផ្លូវភ្នំ ?（1） ក្រឡេកមើលសញ្ញាបង្ហាញពីគីឡូម៉ែត្រ ដើម្បីកំណត់ទីតាំងដែលខ្លួនកំពុងស្ថិតនៅ រួចហើយស្វែងរកជំនួយ （2） ធ្វើដំណើរទៅមុខដើម្បីរកកន្លែងចតដែលមានសុវត្ថិភាពដែលនៅជិតបំផុតដើម្បីស្វែងរកជំនួយបន្ទាន់ ហើយរង់ចាំក្រុមជួយសង្គ្រោះ ។ （3） ទាំងអស់ខាងលើ ។ | 12 |

| | | | |
|---|---|---|---|
| 159 | 3 | ខាងក្រោមនេះ តើណាមួយដែលមិនមែនជាគោលបំណងនៃការត្រួតពិនិត្យចំពោះការបិទផ្លូវ និងស្ពាន? （1） ផ្លូវ និងស្ពាន ងាយនឹងបណ្តាលអោយមានគ្រោះថ្នាក់ ហើយអ្នកបើកបរយានយន្តដែលឆ្លងកាត់ផ្នែកនេះ កំពុងតែដាក់ខ្លួនឯងអោយស្ថិតក្នុងគ្រោះថ្នាក់ធ្ងន់ធ្ងរ ដូច្នេះត្រូវបិទផ្លូវ ឬស្ពាន ជាមុន ដើម្បីចៀសវាងកុំអោយអ្នកបើកបរយានយន្តបើកបរក្នុងតំបន់គ្រោះថ្នាក់នេះ  ដែលអាចនាំទៅដល់ការការស្លាប់បាត់បង់ជីវិត បច្ឆាត់បង់ទ្រព្យសម្បត្តិ（2） ផ្លូវដែលកំពុងសាងសង់ ឬផ្លូវដែលបានខូច គួរតែបិទកុំអោយយានយន្តឆ្លងកាត់ ដើម្បីបង្កើនល្បឿនជួសជុល និងធានាសុវត្ថិភាពដល់អ្នកបើកបរ（3） ការបិទផ្លូវ ឬស្ពា ន បង្ករអោយមានការលំបាកដល់អ្នកបើកបរ និងរំខានដល់ការធ្វើដំណើររបស់ពួកគេ ។ | 12 |
| 160 | 3 | អំពីការគ្រប់គ្រងចម្ងាយចន្លោះយានយន្ត នៅខាងក្រោមនេះ ប្រការណាមិនត្រឹមត្រូវទេ?（1 ）កាលណាយានយន្តបើកបរពីរគ្រឿងជួបគ្នា ចន្លោះខាងឆ្វេងនិងខាងស្តាំមិនអនុញ្ញាតតិចជាងកន្លះម៉ែត្រ （2）ឆ្លងកាត់រថយន្តចតនៅក្បែរផ្លូវជាបណ្តោះអាសន្ន ត្រូវរក្សាចម្ងាយចន្លោះសុវត្ថិភាព១ម៉ែត្រ( ប្រហែលមានប្រវែងស្មើនឹងទ្វារ១) （3）ចាត់ទុកឆ្លងកាតប៉ានជាគោលការណ៍ មិនបាច់គិតគូរដល់ចន្លោះបើកបរទេ។ | 12 |
| 161 | 1 | មត មដួយ សត ុ ល ុកៈឯករលបកបរដចគលន ផដរ គដួរតត 5 វបន រកៈរវង រថយន្ ដចល ុខឯម 8 ខ （1） ល ុ ល១លលវលលដម ឡ បញ ណ ប" អល១អតកក" ១（2）៥ ផមតត ច្យ（3） ច្យ ១០ ផមតត ណមដួយលទ។ | 12 |
| 162 | 3 | អំពីលិខិតបញ្ជាក់ដែលចាំបាច់នាំយកតាមខ្លួននៅពេលជិះម៉ូតូ នៅខាងក្រោមនេះ ប្រការណាមិនត្រឹមត្រូវទេ? （1）ប័ណ្ណបើកបរសំរាប់ម៉ូតូ（2）ប័ណ្ណសំរាប់ម៉ូតូបើកបរ（3）កាតកត់ត្រាពិន្ទុ។ | 12 |

| 題號 | 答案 | 題　　目 | 分類編號 |
|---|---|---|---|
| 163 | 1 | តតម 5 វកររកណត" របស" មតជផមត្រតណត" ទឯន"（1） លបវ ==ុ លភ១នន ៨០ គឡ 5 តកម（2） លដមឡវ ុ=លភ១នន ៤០ គឡ 5 តកម លន（3） តតវ 5 បន កណត" លប ៣០ គឡ 5 តកម។ | 12 |
| 164 | 1 | អំពីការដឹកនាំវត្ថុលើម៉ូតូ នៅខាងក្រោមនេះ ប្រការណាមិនត្រឹមត្រូវទេ?（1 ）អាចដឹកនាំទំនិញមានកំពស់ហួសពីស្មារបស់អ្នកជិះម៉ូតូបាន （2）ទទឹងនៃវត្ថុផ្ទុកមិនអនុញ្ញាតហួសពីជាយដងដៃ១0សង្ទីម៉ែត្រទេ （3）ចំណែកលាតចេញពីកន្ទុយម៉ូតូ ចាប់ពីភ្លៅកង់ មិនអនុញ្ញាតហួសពី៥0សង្ទីម៉ែត្រទេ។ | 12 |
| 165 | 1 | អ្នកជិះម៉ូតូត្រូវតែយកវត្ថុខ្លះជាមួយនឹងខ្លួនឯង រួមមាន:（1） ប័ណ្ណបើកបរ ប័ណ្ណអនុញ្ញាតរថយន្តបើកបរ លិខិតធានាអះអាង（2） អត្តសញ្ញាណប័ណ្ណប្រជារាស្ត្រ（3） កាតសុខភាព ។ | 12 |

| | | | |
|---|---|---|---|
| 166 | 1 | តាំងពីថ្ងៃទី១៥ ខែ៦ ឆ្នាំ២០០៦ ម្ចាស់ម៉ូតូដែលចង់ផ្ទេរកម្មសិទ្ធិម៉ូតូដែលផលិតចេញពីរោងចក្រលើសពី៥ឆ្នាំ ត្រូវតែស្នើសុំធ្វើ<br>(1) ការត្រួតពិនិត្យជាបណ្ដោះអាសន្ន (2) ការត្រួតពិនិត្យតាមពេលកំណត់ (3) ការត្រួតពិនិត្យដោយសារការផ្ទេរកម្មសិទ្ធិ ។ | 12 |
| 167 | 2 | អ្នកចូលការប្រឡងប័ណ្ណបើកបរសំរាប់ម៉ូតូធុនស្រាលឬម៉ូតូធុនធ្ងន់ធម្មតា ត្រូវពេញអាយុ (1) ១៦ឆ្នាំ (2) ១៨ឆ្នាំ (3) ២០ឆ្នាំ ។ | 12 |
| 168 | 2 | តើអ្នកបំពុលដោយអាកុល ថ្នាំស្ពឹកនិងថ្នាំដាស់ អាចចូលការប្រឡងប័ណ្ណបើកបរឬទេ? (1) បាន (2) ទេ<br>(3) ត្រូវតែជាប់ប្រឡងតុល្យភាពលើខ្សែត្រង់ ទើបអាចចូលបាន ។ | 12 |
| 169 | 3 | កាលណាបើកបរយានយន្តលើផ្លូវមានខ្សែផ្លូវពីរដែលមានទិសដៅដូចគ្នា<br>បើសិនជួបរថយន្តឬម៉ូតូបើកនៅខាងមុខលើផ្លូវដែលមានទិសដៅដូចយានយន្តរបស់លោកអ្នក លោកអ្នកត្រូវតែ (1) ចុចស៊ីផ្លេ<br>ដាស់គេបើកចូលផ្លូវសំរាប់យានយន្តល្បឿនយឺត (2) បើកក្បែរគេ ហើយវ៉ាឡានតែម្ដង (3) បើកតាមដាននៅខាងក្រោយ<br>កុំវ៉ាឡានតាមទំនើងចិត្ត ។ | 12 |
| 170 | 1 | ការបើកយានយន្តពីផ្លូវមានពីរខ្សែចូលក្នុងផ្លូវមានមួយខ្សែដែលមានទិសដៅដូចគ្នា ត្រូវតែឱ្យយានយន្តបើកលើផ្លូវត្រង់បើកមុន<br>បើគ្មានយានយន្តបើកត្រង់ ត្រូវ (1) យានយន្តបើកលើផ្លូវខាងក្នុងបើកមុន (2) យានយន្តបើកលើផ្លូវខាងក្រៅបើកមុន<br>(3) យានយន្តល្បឿនលឿនបើកមុន ។ | 12 |
| 171 | 3 | កាលណាម៉ូតូជួបនឹងរថយន្តឬម៉ូតូផ្សេងទៀត ត្រូវរក្សាចម្លោះ យ៉ាងហោចណាស់មិនតិចជាង (1)២ម៉ែត្រ (2)១ម៉ែត្រ<br>(3) 0 ។៥ម៉ែត្រ ។ | 12 |
| 172 | 2 | កាលណាបើកដល់មាត់ផ្លូវខ្វែង បើសិនគ្មានសញ្ញា សញ្ញាបន្ទាត់ សញ្ញាភ្លើងសំរាប់បែងចែកផ្លូវសំខាន់និងសាខាផ្លូវ<br>ត្រូវតែ (1) យានយន្តបើកលើផ្លូវមានខ្សែផ្លូវច្រើនត្រូវផ្អាក ឱ្យយានយន្តបើកលើផ្លូវមានខ្សែផ្លូវតិចបើកមុន<br>(2) យានយន្តបើកលើផ្លូវមានខ្សែផ្លូវតិចត្រូវផ្អាក ឱ្យយានយន្តបើកលើផ្លូវមានខ្សែផ្លូវច្រើនបើកមុន<br>(3) ប្រការខាងលើទាំងអស់ក៏បាន ។ | 12 |

| 題號 | 答案 | 題　　目 | 分類編號 |
|---|---|---|---|
| 173 | 1 | លើផ្លូវមានកោះបែងចែកសំរាប់បែងចែកផ្លូវសំរាប់រថយន្តល្បឿនលឿននិងផ្លូវសំរាប់រថយន្តល្បឿនយឺត<br>យានយន្តដែលបើកលើផ្លូវសំរាប់រថយន្តល្បឿនយឺត មិនអនុញ្ញាត (1) បត់ឆ្វេង (2) បត់ស្ដាំ<br>(3) បត់ឆ្វេងនិងបត់ស្ដាំ ។ | 12 |
| 174 | 2 | លើផ្លូវមានកោះបែងចែកសំរាប់បែងចែកផ្លូវសំរាប់រថយន្តល្បឿនលឿននិងផ្លូវសំរាប់រថយន្តល្បឿនយឺត<br>យានយន្តដែលបើកលើផ្លូវសំរាប់រថយន្តល្បឿនលឿន មិនអនុញ្ញាត (1) បត់ឆ្វេង (2) បត់ស្ដាំ<br>(3) បត់ឆ្វេងនិងបត់ស្ដាំ ។ | 12 |

| | | | |
|---|---|---|---|
| 175 | 2 | ប័ណ្ណបើកបរបានត្រូវដកយក លុបចោល នៅតែបើកបរម៉ូតូ ក្រៅពីពិន័យប្រាក់ ហាមឃាត់អ្នកបើកបរជិះម៉ូតូនៅនឹងកន្លែង ហើយប័ណ្ណបើកបរនេះត្រូវតែ （1）វកំទេចចោលដោយខ្លួនឯង （2）ដកយក ប្រគល់ឱ្យអង្គការមានសមត្ថកិច្ច （3）គ្មានកំណត់ផ្សេងទៀតទេ។ | 12 |
| 176 | 3 | ក្នុងអំឡុងពេលប័ណ្ណបើកបរម៉ូតូត្រូវដកយក នៅតែបើកបរម៉ូតូ ក្រៅពីពិន័យប្រាក់ ហាមឃាត់អ្នកបើកបរជិះម៉ូតូនៅនឹងកន្លែង ហើយត្រូវតែ （1）កត់ត្រាពិន្ទុល្មើសច្បាប់ （2）កត់ត្រាកំណត់ល្មើសច្បាប់ （3）ដកហូតប័ណ្ណបើកបរ។ | 12 |
| 177 | 3 | អ្នកទទួលបានប័ណ្ណបើកបរសំរាប់រថយន្តសណ្តោង រថយន្តដឹកអ្នកដំណើរធំ រថយន្តដឹកទំនិញធំ រថយន្តធុនតូច តែបើកបរម៉ូតូធុនធ្ងន់ នឹងដាក់ទណ្ឌកម្ម （1）ពិន័យប្រាក់ （2）ហាមឃាត់គេបើកបរនៅនឹងកន្លែង （3）រួមប្រការខាងលើទាំងអស់។ | 12 |
| 178 | 3 | អ្នកបើកបរបង្ខំយានយន្តផ្សេងទៀតឱ្យផ្លូវដល់យានយន្តខ្លួនដោយចេតនា ដោយសារវិធីបើកជិតដល់ ប្តូរខ្សែផ្លូវជាបន្ទាន់ ឬវិធីមិនត្រឹមត្រូវផ្សេងទៀត និងបើកបរតាមវិធីគ្រោះថ្នាក់ ហើយបង្កឧប្បត្តិហេតុ នឹងដាក់ទណ្ឌកម្ម （1）ពិន័យប្រាក់ （2）ដកយកប័ណ្ណបើកបរជាបណ្តោះអាសន្ន （3）ពិន័យប្រាក់ ហើយដកហូតប័ណ្ណបើកបរ។ | 12 |
| 179 | 3 | បើសិនមិនដែលជួបស្ថានភាពជាបន្ទាន់ អ្នកបើកបរស្រាប់តែបន្ថយល្បឿន ចាប់ហ្វ្រាំង ឬបញ្ឈប់យានយន្តលើផ្លូវកណ្តាលដោយចេតនា និងបើកបរតាមវិធីគ្រោះថ្នាក់ ហើយបង្កឧប្បត្តិហេតុ នឹងដាក់ទណ្ឌកម្ម （1）ពិន័យប្រាក់ （2）ដកយកប័ណ្ណបើកបរជាបណ្តោះអាសន្ន （3）ពិន័យប្រាក់ ហើយដកហូតប័ណ្ណបើកបរ។ | 12 |
| 180 | 2 | អ្នកបើកបរប្រើប្រាស់ផ្លូវពិសេសសំរាប់កង់ នឹងដាក់ទណ្ឌកម្ម （1）ទូន្មាន （2）ពិន័យប្រាក់ ហើយកត់ត្រាពិន្ទុល្មើសច្បាប់១ពិន្ទុ （3）គ្មានកំណត់ទេ។ | 12 |
| 181 | 3 | តាមធម្មតា មិនអនុញ្ញាតឱ្យមនុស្សបែបណាចូលការប្រឡងប័ណ្ណបើកបរទេ （1）អ្នកជម្ងឺមានស្មារតីអន់ខ្សោយ （2）អ្នកជម្ងឺឆ្កួតជ្រូក （3）រួមប្រការខាងលើទាំងអស់។ | 12 |
| 182 | 3 | មុននឹងចាប់ផ្តើមបើកបរ អ្នកបើកបរត្រូវតែ （1）ចុចស៊ីផ្លេ （2）បើកភ្លើងបង្ហាញទិសដៅ បើកចូលផ្លូវឱ្យបានឆាប់ （3）បើកភ្លើងបង្ហាញទិសដៅ ប្រុងប្រយ័ត្នចំពោះខាងមុខ ក្រោយ ឆ្វេង ស្តាំ មើលមើល៍មានឧបសគ្គឬយានយន្ត និងអ្នកដំណើរឬទេ។ | 12 |

| 題號 | 答案 | 題　　目 | 分類編號 |
|---|---|---|---|
| 183 | 3 | កាលណាជួបសភាពការណ៍ជាបន្ទាន់ឬគ្រោះថ្នាក់ ត្រូវចុចស៊ីផ្លេ ហើយគោរពតាមគោលការណ៍ចុចស៊ីផ្លេម្តង ហើយ （1）មិនត្រូវតែបន្តចុចស៊ីផ្លេ៣ដង （2）រាល់ដងមិនត្រូវតែហួសពីកន្លះវិនាទី （3）រួមប្រការខាងលើទាំងអស់។ | 12 |

| | | | |
|---|---|---|---|
| 184 | 2 | កាលណាម៉ូតូត្រូវតែបើកបរលើខ្សែផ្លូវ ត្រូវតែគោរពតាមកំណត់នៃសញ្ញាឬបន្ទាត់សញ្ញា បើសិនគ្មានសញ្ញាឬបន្ទាត់សញ្ញា ត្រូវតែ (1)អាចបើកលើផ្លូវសំរាប់អ្នកដំណើរដើរ (2)មិនត្រូវតែបើកលើផ្លូវសំរាប់អ្នកដំណើរដើរ (3)គ្មានកំណត់ទេ។ | 12 |
| 185 | 3 | កាលណាបើកដល់មាត់ផ្លូវខ្វែង បើសិនចង់បត់ឆ្វេង(ស្តាំ) ត្រូវបើកភ្លើងបង្ហាញទិសដៅឬធ្វើកាយវិការដៃនៅខាងមុខប៉ុន្មានម៉ែត្រពីមាត់ផ្លូវខ្វែង? (1)១0ម៉ែត្រ (2)២0ម៉ែត្រ (3)៣0ម៉ែត្រ។ | 12 |
| 186 | 2 | កាលណាបើកយានយន្តជិតដល់ផ្លូវសំរាប់អ្នកដំណើរឆ្លងកាត់ដែលគ្មានសញ្ញាភ្លើងគ្រប់គ្រងយានយន្ត ត្រូវតែ (1 )បង្កើនល្បឿនឆ្លងកាត់ (2)បន្ថយល្បឿនបើកយឺត១ (3)គ្មានកំណត់ទេ។ | 12 |
| 187 | 3 | ក្នុងករណីណា ពេលបើកបរត្រូវតែបើកភ្លើងក្បាល? (1)ពេលជួបអ័ព្ទក្រាស់ឬធ្លាក់ភ្លៀង (2)មេឃងងឹតឬមើលមិនច្បាស់លាស់ (3)រួមប្រការខាងលើទាំងអស់។ | 12 |
